Formation, Dialogue, Cooperation

# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៨ សម្រាប់ខែមេសា ឆ្នាំ២០១៦ លក់តម្លៃ ១០០០រៀល

លេខ ៩៣

# បុណ្យចម្លង២០១៦ មនុស្សពេញវ័យ ២២៥នាក់ទទួលជ្រមុជទឹក



## សេចក្តីជូនដំណឹង

" លោហិតមរណសាក្សី គឺគ្រាប់ពូជរបស់ព្រះសហគមន៍ " (Apologeticus, Chapter 50:Tertullian)។ បងប្អូនជាទីស្រឡាញ់ ព្រះសហគមន៍កាតូលិកកម្ពុជារីកចម្រើនដោយសារឈាមមរណសាក្សី។ ខ្ញុំលោកបូជាចារ្យ រឿង ផ៉ត្រសិរី អ្នករៀបចំសំណុំរឿង (Postulator) បានប្រមូលព័ត៌មានមួយចំនួនហើយ ប៉ុន្តែសូមបងប្អូនជួយផ្តល់ព័ត៌មានបន្ថែមអំពី អ្នកបម្រើរបស់ព្រះជាម្ចាស់ថែមទៀតដូចជា រូបថត អត្ថបទឬសៀវភៅដែលគាត់សរសេរវត្ថុអនុស្សាវរីយរបស់គាត់ខ្លះ ។ល។ សូមផ្តល់ឈ្មោះអ្នកដែលអាចផ្តល់សក្ខីភាពបានជូនមកឲ្យខ្ញុំតាមរយៈអាសយដ្ឋានខាងក្រោម

Tel : 077 800 211 / 096 34 22 144 ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ Email: martyrscambodia@gmail.com

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

CARITAS CHRISTI URGET NOS

**ព្រះសហគមន៍កាតូលិកនៅព្រះរាជាណាចក្រកម្ពុជា**
**ភូមិភាគភ្នំពេញ**

លេខ: ២២/២០១៦ - អក

# លិខិតថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ

**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

សូមក្រាបបង្គំទូលថ្វាយ

**សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ**
**ព្រះវររាជមាតាជាតិខ្មែរ**
**ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល**

ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំវក អដ្ឋស័ក ព.ស ២៥៦០ ដែលនឹងឈានចូលមកដល់នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៦ ខាងមុខនេះ ទូលព្រះបង្គំយើងខ្ញុំ ជាអភិបាល បូជាចារ្យ បព្វជិត បព្វជិតា រួមជាមួយគ្រីស្តបរិស័ទនៃព្រះសហគមន៍កាតូលិកក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា មានសេចក្តីសោមនស្សរីករាយ និងមហាកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ សូមទ្រង់ព្រះមេត្តាប្រសិទ្ធពរជ័យបវរមហាប្រសើរ

**ថ្វាយ**
**ព្រះករុណា ព្រះបាទសម្តេច**
**ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**
**និង**
**សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ**
**ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល**

សូមព្រះករុណា និង សម្តេចព្រះមហាក្សត្រី ព្រមទាំងព្រះរាជវង្សានុវង្ស សូមបានប្រកបដោយព្រះរាជសុខភាពល្អបរិបូណ៌ ព្រះរាជកាយពលមាំមួន ព្រះរាជបញ្ញាញាណភ្លឺត្រចះត្រចង់ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់លើព្រះរាជបល្ល័ង្គ ជាម្លប់ដ៏ត្រជាក់ត្រជុំ សុខក្សេមក្សាន្ត ចម្រុងចំរើនរុងរឿង ដល់ប្រជានុរាស្ត្ររបស់ព្រះអង្គជានិច្ចនិរន្តរ៍តរៀងទៅ។

សូម ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង និង សម្តេចព្រះមហាក្សត្រី ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីដ៏ខ្ពង់ខ្ពស់ និងជ្រាលជ្រៅបំផុត ពីព្រះសហគមន៍កាតូលិកកម្ពុជា។

ក្រាបបង្គំទូលថ្វាយពីរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០១៦
អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ

អូលីវីយេ ឝ្មីតហាស្លេ


CSC
Formation, Dailouge, Cooperation
**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក**
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
**ចាងហ្វាង : លោក លី សុវណ្ណា**
សេចក្តីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# រីករាយបុណ្យចម្លង អាលេលូយ៉ា អាលេលូយ៉ា ! សួស្តីឆ្នាំថ្មី !



លោកលីសុវណ្ណា
ចាងហ្វាងកាសែតអ្នកនាំសារ

សង្គមកម្ពុជាពីមួយថ្ងៃទៅមួយថ្ងៃកាន់តែវិវដ្តទៅមុខឥតឈប់ឈរ។ បរិបទនយោបាយក្តៅគ្រជាក់ជាធម្មតា។ ស្ថេរភាពសន្តិភាពបានជំរុញឲ្យល្បឿននៃការអភិវឌ្ឍកម្ពុជាកាន់តែមានសន្ទុះទៅមុខជានិច្ច។

មួយរយៈពេលចុងក្រោយនេះ គឺកាន់តែមានភាពល្អប្រសើរឡើងថែមទៀត គឺដោយសារសំលេងយុវជន និស្សិត ត្រូវបានស្ថាប័នកំពូលរបស់ព្រះរាជាណាចក្រកម្ពុជាយកចិត្តទុកដាក់យ៉ាងខ្លាំង។ តាមរយៈការឆ្លើយតបភ្លាមៗ ចំពោះការដាក់ញត្តិឬពាក្យបណ្តឹងនានារបស់យុវជនមួយក្រុមដែលតាំងខ្លួន ជាតំណាងឲ្យនិស្សិតតាមមហាវិទ្យាល័យនានាក្នុងរាជធានីភ្នំពេញដែលបានចេញមុខការពារសីលធម៌ សុជីវធម៌ និងវប្បធម៌ដ៏ផូរផង់របស់ខ្មែរ។ យុវជនទាំងនោះបានប្តឹងទៅកាន់អង្គភាពប្រឆាំងអំពើពុករលួយ និងដាក់ញត្តិទៅកាន់រដ្ឋសភាជាតិ ដើម្បីឲ្យតំណាងរាស្រ្តម្នាក់ចេញបកស្រាយទៅលើខ្សែអាត់សំលេងដែលគេបានសម្មត់ថាជាសំលេងតំណាងរាស្តម្នាក់នោះ មកពីគណបក្សក្រៅរាជរដ្ឋាភិបាល គឺលោកកឹម សុខា។ ក្នុងខ្សែអាត់សំលេងនេះ គឺបុរសម្នាក់បាននិយាយសាសងស្នេហាស៊ីចម្រៅជាមួយនារីម្នាក់ ដែលក្រុមនិស្សិតទាំងនោះចាត់ទុកថាជាការប្រព្រឹត្តខុសសីលធម៌ និងប្រពៃណីរបស់ខ្មែរ ព្រោះខ្លួនមានគ្រួសារហើយលួចមានស្រីទៀត។

ខ្សែអាត់សំលេងនេះវែងអន្លាយតភាគដូចរឿងភាគចិន "ឋាំងឆេងទៅចំលងធម៌" រហូតដល់ពេលនេះដល់ភាគទី៤១។

យុវជនដែលតាំងខ្លួនជានិស្សិតការពារវប្បធម៌ បានខិតខំទៅរកតួអង្គដែលគេចាត់ទុកជាម្ចាស់សំលេង ដើម្បីឲ្យបកស្រាយថាពិត ឬមិនពិត។ ពួកបានទៅគ្រប់កន្លែងដែលមានវត្តមានរបស់លោក កឹម សុខា ។

ពួកគេហែក្បួន យកញត្តិទៅដាក់នៅរដ្ឋសភា ទៅស្នាក់ការគណបក្សសង្គ្រោះជាតិ និងយកពាក្យបណ្តឹងទៅកាន់អង្គភាពប្រឆាំងអំពើពុករលួយជាដើម។ សកម្មភាពទាំងនេះ គឺអាជ្ញាធរមិនបានរារាំងឡើយ ស្ថាប័នកំពូលៗបានទទួលយកនិងចាត់វិធានការភ្លាមៗដែរលើកករណីអសីលធម៌នេះ។ នេះជាសញ្ញាដ៏ប្រសើរបំផុតសម្រាប់យុវនិស្សិតក្នុងការស្វែងរកអន្តរាគមន៍ដើម្បីប្រយោជន៍សង្គម។ តើយុវនិស្សិតក្រុមនេះនឹងរកយុត្តិធម៌សម្រាប់ជនរងគ្រោះដោយការរំលោភដីធ្លីបានដែរទេ? ចុះចំពោះអំពើអសកម្មក្នុងសង្គមរបស់មន្ត្រីមូលដ្ឋាន ឬមន្ត្រីជំនាញវិញ? ការពារសិទ្ធិមនុស្សយ៉ាងណាដែរ? ការពារព្រៃឈើ ការពាររ៉ែ ធនធានធម្មជាតិ ត្រី តើយ៉ាងណាខ្លះ? ប្រឆាំងអំពើពុករលួយ ភូមិឃុំមានសុវត្ថិភាព និងអំពើអយុត្តិធម៌សង្គម?

ហេតុនេះសកម្មជន ព្រៃឈើ បរិស្ថាន ដីធ្លី សហជីព និងសកម្មជនការពារសិទ្ធិមនុស្សជាដើម គួររៀនពីរបៀបដែលនិស្សិតទាំងនេះបានធ្វើក្នុងការតវ៉ា ឬដាក់ញត្តិទៅកន្លែងណាមួយក្នុងស្ថានប័នរបស់ជាតិ ជៀសវៀងការរារាំង ការចាប់ខ្លួនពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច។

ទោះបីជាសកម្មភាពយុវជនមួយក្រុមនេះ ត្រូវបានមតិមហាជនមួយចំនួនយល់ថា ជាក្រុមដែលចាត់តាំងឡើងដោយអ្នកនយោបាយ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយនេះគឺជាការបង្ហាញនូវតួនាទីយុវជនមួយដែលសង្គមកម្ពុជាបានទទួលស្គាល់ ដូច្នេះដើម្បីឲ្យយុវជនគ្រប់រូបក្នុងសង្គមប្រជាធិបតេយ្យ មានសិទ្ធិនិង មានតម្លៃថែមទៀតនៅក្នុងសង្គម នាឆ្នាំក្រោយយុវជនគួរតែស្វ័យសិក្សារៀនសូត្រ និងចូលរួមសកម្មភាពនានាឲ្យកាន់តែផុលផុសថែមទៀត នៅក្នុងក្របខណ្ឌនៃច្បាប់ដើម្បីឲ្យសង្គមយើងអាចអភិវឌ្ឍន៍ទៅមុនប្រកបដោយនិរន្តរភាព ។

សួស្តីឆ្នាំថ្មី! ឆ្នាំថ្មី យើងចង់ឃើញ យុវជនកម្ពុជាយើងកាន់តែសកម្ម មានតម្លៃថែមទៀតនៅក្នុងដំណើរការអភិវឌ្ឍន៍នៃសង្គមកម្ពុជា នៅក្នុងចរន្តនៃការធ្វើសមាហរណកម្មតំបន់ និង ពិភពលោក ។

សូមព្រះជាម្ចាស់ប្រទានពរ ជូនបងប្អូន ....!

# ពិធីបុណ្យឆ្លងព្រះវិហារសន្តអន់ ដ្រេ នៃព្រះសហាគមន៍កាតូលិកនិគម



លោកអភិបាលនិងលោកបូជាចារ្យប្រោះទឹកព្រះពរជុំវិញព្រះវិហារថ្មី។ ដោយឬទ្ធីរដ្ឋ

ព្រះសហគមន៍កាតូលិកនិគម បានរៀបចំពិធីឆ្លងព្រះវិហារដែលមានឈ្មោះថា ព្រះវិហារសន្តអន់ដ្រេ ស្ថិតឃុំជ្រោយស្តៅ ស្រុកថ្មគោល ខេត្តបាត់ដំបង ក្រោមអធិបតីភាពរបស់លោកហ្វីការេដូ អេនរីគេ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង រួមជាមួយលោកបូជាចារ្យ និងគ្រីស្តបរិស័ទជាង៨០០នាក់ កាលពីថ្ងៃទី៣១ ខែមីនា កន្លងទៅ។

លោកអភិបាលអេនរីគេ មានប្រសាសន៍ថា ព្រះវិហារថ្មីនេះគឺជាការលើកទឹកចិត្តមួយសម្រាប់បងប្អូនគ្រីស្តបរិស័ទទីនេះ នាំឲ្យបងប្អូនមានអំណរសប្បាយដោយរួមគ្នាធ្វើដំណើរទៅខាងមុខ។ លោកអភិបាលបន្តថា នៅទីនេះ យើងមានទីកន្លែងស្អាត មានទីកន្លែងមួយដ៏សមរម្យដើម្បីលើកតម្កើងព្រះជាម្ចាស់។ លោកអភិបាល "គឺបងប្អូនអាចជួបជុំគ្នាថ្វាយអភិបូជា និងទទួលអគ្គសញ្ញានានាដែលនាំឲ្យបងប្អូននៅក្នុងភូមិនិគមទទួលស្គាល់អំពីវត្តមានព្រះជាម្ចាស់"។

លោកបូជាចារ្យ កុមារ ម៉ានុច ឯកាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍និគមបានមានប្រសាសន៍ថា សម្រាប់ព្រះសហគមន៍និគម គឺជាព្រះអំណោយទានរបស់ព្រះជាម្ចាស់ តាមរយៈបងប្អូននិងគ្រីស្តបរិស័ទ។

លោកបូជាចារ្យរូបនេះ បានបញ្ជាក់បន្តថា តាមរយៈការសាងសង់ព្រះវិហារនេះ យើងមើលឃើញថា ម្ចាស់ជំនួយរូបនេះលោកជាមនុស្សល្អបំផុត មិនមែនដោយសារតែរូបគាត់ជួយថវិកាក្នុងការសាងសង់ព្រះវិហារនោះទេ ប៉ុន្តែលោកជាមនុស្ស ដែលមានបេះដូងធំណាស់សម្រាប់អ្នកក្រីក្រ និងសម្រាប់យើងឲ្យមានកន្លែងអធិដ្ឋាន។

ព្រះសហគមន៍នេះ បានកកើតឡើងក្រោយពេលមានការធ្វើមាតុភូមិនិវត្តន៍របស់បងប្អូនមកពីជំរំខ្មែរ-ថៃ ដោយមានតែគ្រួសារគ្រីស្តបរិស័ទចំនួន ២គ្រួសារ។

បច្ចុប្បន្នព្រះសហគមន៍និគមមានគ្រីស្តបរិស័ទប្រមាណជិត២០នាក់។ ព្រះវិហារសន្តអន់ ដ្រេ នៃព្រះសហគមន៍កាតូលិកនិគម ឧបត្ថម្ភថវិកាពីលោកម៉ាកូស អាន់ មកពីប្រទេសកូរ៉េ ៕

ដោយ ឡុង សម្ផស្ស

# រាស្ត្ររង់ចាំមើលចំណាត់ការអាជ្ញាធររឿងអសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ




*ស្លាកបនមីក្រូហិរញ្ញវត្ថុមួយកន្លែងនៅតាមបណ្តោយផ្លូវជាតិលេខ៥។ ថតដោយសហការី*

អង្គុយនៅលើម៉ូតូក្រោមដើមឈើមួយដើមនៅម្តុំទួលស្វាយព្រៃដៃកាន់វិទ្យុ និងត្រចៀកផ្ទៀងផ្ទាត់ស្តាប់ប្រសាសន៍ប្រមុខរដ្ឋាភិបាលកម្ពុជា ដែលបានថ្លែងនៅក្នុងពិធីបើកសន្និសីទជាតិស្តីអំពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ កាលពីថ្ងៃទី១៤ មីនា ២០១៥ លោក រុន ណារុណ ប្រជាពលរដ្ឋកម្ពុជាវ័យចំណាស់មួយរូបដែលកំពុងរង់ចាំទទួលភរិយារបស់លោកបានអះអាងថា ប្រសិនបើធនាគារជាតិអាចអនុវត្តតាមអនុសាសន៍រឿងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពលរដ្ឋមួយចំនួននឹងសប្បាយចិត្ត។

លោកបានបញ្ជាក់ថា "អ្ហែ! បើតាមខ្ញុំតាមដានកន្លងមក គ្រប់អនុសាសសន៍គ្រប់វិធានការដែលប្រមុខរដ្ឋាភិបាលដាក់ចេញគឺល្អ តែទាស់តែរឿងអនុវត្តន៍តែប៉ុណ្ណោះ"។

លោកបន្តទៀតថា "គាត់(ប្រមុខរដ្ឋាភិបាល)និយាយពីរោះ ហើយត្រូវចំបញ្ហាច្រើនខ្ញុំចូលចិត្តស្តាប់ ប៉ុន្តែទាស់តែអ្នកនៅខាងក្រោម មិនអនុវត្តន៍ឲ្យម៉ឺងម៉ាត់"។

ថ្លែងនៅវិមានសន្តិភាព សម្តេចតេជោ ហ៊ុន សែន បានបញ្ជាឲ្យមានចំណាត់ការលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុណាដែលមានចេតនារឹបអូសទ្រព្យប្រជាជន។

នៅក្នុងពិធីនោះ សម្តេចតេជោ ហ៊ុន សែន បានបញ្ជាឲ្យមានចំណាត់ការជាបន្ទាន់ទៅកាន់អង្គការក្រៅរដ្ឋាភិបាលមួយចំនួនដែលបានប្រែក្លាយទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហើយមានចេតនារឹបអូសយកដីធ្លីនិងទ្រព្យសម្បត្តិប្រជាពលរដ្ឋ តាមរយៈភាពធូរលុងក្នុងការឲ្យពលរដ្ឋខ្ចីប្រាក់ដោយមិនពិនិត្យមើលលទ្ធភាពនៃការសងបំណុល និងមិនបានសិក្សាឲ្យបានលម្អិតអំពីគោលដៅនៃការខ្ចីប្រាក់។

សម្តេចតេជោ ហ៊ុនសែន បានថ្លែងហើយបញ្ជាឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងធនាគារជាតិពិនិត្យមើលបញ្ហាទាំងអស់នេះឡើងវិញ ។

សម្តេចតេជោ ហ៊ុន សែនបានសង្កត់ធ្ងន់ថា ពាក់ព័ន្ធនឹងការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពធនាគារដោយពុំទាន់មានច្បាប់អនុញ្ញាតនាពេលកន្លងមកមានអង្គការមិនមែនរដ្ឋាភិបាល សមាគមនិងឈ្មួញឱ្យខ្ចីចងការប្រាក់ក្រៅប្រព័ន្ធបានចាត់ទុកខ្លួនឯងជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្របច្បាប់ ដោយយកអត្រាការប្រាក់កម្ចីខ្ពស់ ប្រើវិធីសាស្ត្រគណនាសងប្រាក់កម្ចីមានលក្ខណៈកេងបន្លំ និងកេងប្រវ័ញ្ច នីតិវិធីនៃការខ្ចីប្រាក់មានភាពធូររលុង និងឆាប់រហ័សដែលកត្តាទាំងនេះបានជំរុញឱ្យប្រជាជនទទួលបានប្រាក់កម្ចីពីប្រភពទាំងនោះភាគច្រើនត្រូវជាប់បន្ទុកបំណុលវ័ណ្ឌក និងគ្មានលទ្ធភាពសងបំណុលវិញ។ ជាលទ្ធផលទ្រព្យបញ្ចាំដែលរួមមាន ដីធ្លី ផ្ទះសម្បែង ដីស្រែត្រូវបានអង្គការ សមាគម ឬឈ្មួញទាំងនោះរឹបអូស។

សម្តេចតេជោមានប្រសាសន៍ទៀតថា ជាធម្មតាគោលការណ៍សម្រាប់ការឲ្យខ្ចីគេតែងតែពិនិត្យកូនបំណុលថា តើគេមានសមត្ថភាពសងឬអត់ពីគោលដៅនៃការខ្ចី ប៉ុន្តែនេះអត់ ស្ថាប័នខ្លះហាក់ដូចជាមានចេតនារឹបអូសយកផ្ទះសម្បែង និងដីធ្លីតែម្តង។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា "ជួនកាលគេខ្ចីយកទៅទិញម៉ូតូជិះលេង។ ដល់ជិះលេងទៅវាមានលទ្ធភាពសងមកពីណាក៏ចេះតែឲ្យដែរ។ តែដល់ពេលកំណត់គឺចាប់ផ្តើមរឹបអូសយកផ្ទះសម្បែងដីធ្លីគេតែម្តង"។

សម្តេចតេជោ ហ៊ុន សែន បានបន្តទៀតថា ស្ថាប័នមីក្រូហិរញ្ញវត្ថុមួយចំនួនគឺមានចេតនាបោកប្រជាពលរដ្ឋតែម្តង ហើយបានបញ្ជាកុំឲ្យសមត្ថកិច្ចសហការជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុដែលមានបំណងរឹបអូសដីធ្លីរបស់ប្រជាពលរដ្ឋលើកលែងតែមានច្បាប់មានដីកាតុលាការត្រឹមត្រូវតាមច្បាប់ ។

លោក ណារុណ បានបន្តទៀតថា អារឿងខ្ចីលុយអង្គការ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ) ដែលគាត់(សម្តេចតេជោ)បានដឹងបាននិយាយ គឺជារឿងដែលពិត ដូច្នេះបើអាជ្ញាធរចាត់វិធានការតាមប្រសាសន៍នោះគឺនឹងអាចជួយប្រជាពលរដ្ឋនៅមូលដ្ឋានបាន ។

លោកបន្តទៀតថា ដូចរូបលោក ដែលធ្លាប់ខ្ចីធនាគារយកទុនមករកស៊ី គេសួរតាំងពីការងារ ពិនិត្យមើលចំណូល ចំណាយប្រចាំខែ... តែនៅជនបទ មានការសាកសួរនិងសិក្សាករណីនេះដូចគ្នា តែភាគច្រើនធ្វើលំៗបង្គ្រប់កិច្ចតែប៉ុណ្ណោះ។

លោក ជូ ដេតរដ្ឋា ជាអ្នករត់ម៉ូតូឌុបមួយរូបមកពីខេត្តព្រៃវែង បានឲ្យដឹងថា នៅឯស្រុកកំណើតរបស់លោកនៅស្រុកមេសាងអង្គការ(ស្ថាប័នមីក្រូហិរញ្ញវត្ថុ) មានច្រើនណាស់ ការិយាល័យក៏ច្រើន មន្ត្រីគេក៏ច្រើនមួយថ្ងៃៗជិះម៉ូតូឆ្វេងឆ្វាត់ដើរតែអន្ទងប្រជាពលរដ្ឋឲ្យខ្ចីប្រាក់ ។

លោកបានបន្តទៀតថា រូបលោកក៏ជាកូនបំណុលរបស់អង្គការមួយរូបនឹងគេដែរ ដោយប្រពន្ធលោកជាអ្នកខ្ចីនៅឯស្រុកយកទៅទិញម៉ូតូឲ្យកូន។ លោកបានបញ្ជាក់ថា "ខ្ញុំរវល់តែរត់ម៉ូតូនៅទីនេះ (ភ្នំពេញ) តែម៉ែវានៅឯស្រុកគេថា ទើបតែយកលុយពីអង្គការ៣លាន"។

តាមរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជាបានឲ្យដឹងថា រហូតដល់ឆ្នាំ២០១៥នេះ កម្ពុជាមានធនាគារពាណិជ្ជចំនួន៣៦ ធនាគារឯកទេសចំនួន ១១ ការិយាល័យតំណាងធនាគារបរទេស៨ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ៥៨ ប្រតិបត្តិករឥណទានជនបទ ១០៤ ក្រុមហ៊ុន។ អ្នកដែលដាក់ប្រាក់បញ្ញើមាន ៤លាននាក់ កើន២១,៧ភាគរយ ហើយអ្នកដែលជំពាក់លុយធនាគារមាន ២,៥ លាននាក់ មានកំណើន១៤,១៤ភាគរយ។

រហូតមកដល់ពេលបច្ចុប្បន្ននេះក្នុងចំណោមបណ្តាស្ថាប័នហិរញ្ញវត្ថុ ទាំងនេះ គឺនៅមិនទាន់មានស្ថាប័នណាមួយ ឬក៏ប្រតិបត្តិករហិរញ្ញវត្ថុឬក៏បុគ្គលណាម្នាក់ដែលត្រូវបានផ្តន្ទាទោស ឬ ក៏ចាត់វិធានការផ្លូវច្បាប់ ដោយសារតែបញ្ហាអសកម្មនៃកម្មវិធីឥណទាននេះនៅឡើយទេ។

អ្វីដែលបានឃើញកាលពីពេលកន្លងមក គឺគ្រាន់តែជាការព្រមានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុព្រមទាំងធនាគារជាតិនៃកម្ពុជាទៅលើអង្គការក្រៅរដ្ឋាភិបាលឬប្រតិបត្តិផ្នែកហិរញ្ញវត្ថុដែលមិនមានច្បាប់ដើម្បីឲ្យពួកគេទៅស្នើសុំច្បាប់តែប៉ុណ្ណោះខណៈ ដែលប្រតិបត្តិករទាំងនោះកំពុងតែបង្កើនសកម្មភាពទីផ្សាររបស់ពួកគេនៅពាសពេញប្រទេស ហើយនៅពេលនេះបណ្តាស្ថាប័នទាំងនេះបានពង្រីករហូតដល់កម្រិតស្រុកដោយស្ថាប័នខ្លះ គឺមានរហូតដល់ឃុំ ផងក៏មាន។

*ដោយអរិយបុត្រ*

# យុវជនចងចាំបុណ្យបច្ចឹមប្រទេសជាងប្រពៃណីជាតិមួយចំនួន




*យុវជនចូលរួមកម្មវិធីសប្បុរសធម៌លើកទី៧ក្នុងថ្ងៃបុណ្យទិវានៃក្តីស្រឡាញ់ នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងថ្ងៃទី១៤ កុម្ភៈ ២០១៦។ ថតដោយពិសិទ្ធ*

ខណៈដែលប្រជាពលរដ្ឋកម្ពុជា ត្រូវបានឈប់សម្រាកបុណ្យមាឃបូជាកាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៦ យុវជនកម្ពុជាមួយចំនួនបានអះអាងថា ពួកគេមិនបានដឹងថា តើថ្ងៃនេះឈប់សម្រាកដោយសារពិធីបុណ្យអ្វីនោះទេ។

យុវសិស្សវិទ្យាល័យទទួលទំពូងមួយរូបបានអះអាងថា ប្អូនមិនបានដឹងថា តើថ្ងៃនោះឈប់សម្រាកអ្វីនោះទេ គ្រាន់តែថាលោកគ្រូបានឲ្យឈប់សម្រាកមួយថ្ងៃប៉ុណ្ណោះ។

យុវជនរូបនេះបានបញ្ជាក់ថា "ខ្ញុំអត់បានមើលកាឡង់យេ(ប្រតិទិន)ផង តែមិត្តភក្តិ និងលោកគ្រូអ្នកគ្រូគាត់ថា ឈប់សម្រាកមួយថ្ងៃ"។

សម្រាប់បុណ្យប្រពៃណីជាតិមួយចំនួនដែលរដ្ឋតម្រូវ និងអនុញ្ញាតឲ្យឈប់សម្រាក ដូចជាបុណ្យច្រត់ព្រះនង្គ័ល និងបុណ្យផ្សេងៗជាដើមនោះ គឺយុវជនកម្ពុជាហាក់មិនចាំនោះទេ ប៉ុន្តែនៅពេលដែលសួរថា តើថ្ងៃណាថ្ងៃបុណ្យនៃក្តីស្រលាញ់ ឬថ្ងៃណាថ្ងៃបុណ្យណូអែល បុណ្យចូលឆ្នាំសកល ដែលមិនមែនជាបុណ្យប្រពៃណី គឺប្អូនៗបានឆ្លើយយ៉ាងរហ័សដោយអត់រុញរាថា ថ្ងៃទី១៤ ខែកុម្ភៈ ថ្ងៃទី ២៥ ខែ ធ្នូ និងថ្ងៃ ទី០១ ខែមករារៀងមក ហើយថែមទាំងបញ្ជាក់ថា នេះជាថ្ងៃសាមញ្ញដែលនរណាក៏អាចចាំបានដែរ ។

យុវជនខាងលើបានអះអាងថា អត់មានការឈប់សម្រាកអ្វីនោះទេ តែនេះគឺជាព្រឹត្តិការដែលដក់ជាប់ ដោយសារតែឲ្យតែថ្ងៃនោះ គឺប្អូនបានឃើញនូវទិដ្ឋ-ភាពនោះរាល់ឆ្នាំដដែលៗ ខណៈដែលបុណ្យជាតិផ្សេងៗ គឺប្អូនកម្របានឃើញណាស់ គឺមានតែនៅក្នុងទូរទស្សន៍ ។

យុវជនរូបនោះបន្តថា "ដូចបុណ្យនៃក្តីស្រលាញ់ឥចឹង ខ្ញុំឃើញគេលក់ផ្កា ទិញផ្កា ហើយជូនផ្កា ទិញកាដូរឲ្យគ្នារាល់តែឆ្នាំក៏ចាំតែម្តង ខណៈបុណ្យសាសនាផ្សេងៗខ្ញុំមិនដែលបានចូលរួមផង ដូច្នេះហើយបានជាមិនចងចាំ"។

**"ជាទូទៅសម្រាប់អត្ថន័យ[...]ក៏មិនមែនថាយុវជនហើយនិងខ្ញុំមិនដឹងនោះទេ គ្រាន់តែមិនបានយកចិត្តទុកដាក់"**

ប្អូនបានបញ្ជាក់ទៀតថា "ខ្ញុំឃើញគេលេង (ក្នុង)បុណ្យនៃក្តីស្រលាញ់ បុណ្យណូអែល នេះតាំងតែពីខ្ញុំនៅតូច តែបុណ្យមាឃបូជាអី មិនដែលឃើញ ហើយក៏មិនសូវឮគេនិយាយគ្នាទៀត"។

លីន អៀង ជាយុវសិស្សវិទ្យាល័យមួយរូបបានឲ្យដឹងថា ត្រឹមតែថ្ងៃឈប់សម្រាកគឺប្អូនដឹង ហើយនៅពេលដែលជួបសំភាសន៍ កាលពីថ្ងៃមាឃបូជា ប្អូនក៏អាចដឹងថា ថ្ងៃនេះឈប់សម្រាកដែរ ដោយសារឮគេនិយាយគ្នា ហើយផ្ទះប្អូននៅជិតវត្តតែប៉ុណ្ណោះ រីឯអត្ថន័យនៃបុណ្យនេះយ៉ាងណានោះគឺ ប្អូនបានត្រឹមតែសូមទោសប៉ុណ្ណោះ ហើយអះអាងថា ប្អូនមិនទាន់ស៊ីជម្រៅ។

យុវជនរូបនេះបានបញ្ជាក់ថា "ត្រឹមថ្ងៃសីលថ្ងៃអីពិសេសៗ គឺខ្ញុំដឹង តែទាំងអស់ហ្នឹង ដោយសារ ខ្ញុំឃើញគេលក់ផ្កាលក់ផ្លែឈើ និងឃើញចាស់ៗទៅវត្តដោយសាផ្ទះខ្ញុំក្បែរវត្ត"។

តាមឯកសារបានឲ្យដឹងថា មាឃបូជាគឺជាពិធីបុណ្យដ៏សំខាន់មួយរបស់ព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋដែលរដ្ឋធម្មនុញ្ញបានចែង។ ពិធីបុណ្យនេះគឺត្រូវបានប្រជាពលរដ្ឋកម្ពុជាប្រារព្ធឡើងដើម្បីរំឭកដល់ព្រឹត្តិការណ៍សំខាន់ៗនៅក្នុងព្រះពុទ្ធសាសនា ដូចជារំឭកដល់ថ្ងៃចតុរង្គសន្និបាតនៃព្រះភិក្ខុសង្ឃ ទាំង ១២៥០អង្គនាថ្ងៃ១៥កើត ខែមាឃ និងរំឭកដល់ថ្ងៃព្រះសម្មាសម្ពុទ្ធ ដែលទ្រង់បានដាក់អាយុសង្ខារ ពោលគឺថ្ងៃ១៥កើត ខែមាឃនេះ ជាថ្ងៃដែលព្រះពុទ្ធព្រះបរមគ្រូបានត្រាស់ដឹង និងក៏ជាថ្ងៃដែលព្រះអង្គបានចូលបរិនិព្វាន។

លីន អៀង ដែលមានគេហដ្ឋាននៅក្បែរវត្តទួលសង្កែ បានបន្តចែករំលែកថា មូលហេតុដែលប្អូននិងមិត្តភក្តិពិបាកនឹងចងចាំពិធីបុណ្យទាំងនេះ គឺដោយសារម្នាក់ៗមិនដែលបានចូលរួមពិធីបុណ្យបែបសាសនានោះទេ ដូច្នេះហើយបានជាមិនសូវចាំ លើកលែងតែអ្នកដែលគេនិយមអាននិងមើលឯកសារច្រើន ។

ចេង មុនីសិត្យា ជាយុវនិស្សិតមួយរូបនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានឲ្យដឹងថា បានត្រឹមតែអានម្តងពីរដងគឺធម្មជាតិមនុស្សពិបាកនឹងចងចាំបានណាស់ ទាល់តែឃើញហើយប្រតិបត្តិរាល់ដងទើបបានអាចឲ្យអង្គចងចាំ និងអាចចងចាំនេះបានយូរ។

សិត្យា បានបន្តថា ប្អូនធ្លាប់រៀនធ្លាប់បានអានឯកសារទាក់ទងនឹងព្រះរាជពិ-ធីបុណ្យជាតិនានា ប៉ុន្តែបើឲ្យចាំដូចបុណ្យនៃក្តីស្រលាញ់ បុណ្យណូអែលដែលគេប្រតិបត្តិរាល់តែឆ្នាំហើយទាំងខ្ញុំទាំងគេរីករាយជាមួយគ្នារាល់តែឆ្នាំ គឺរមែងចាំនិងរមៃពីបុណ្យនេះ ដោយឡែកបុណ្យប្រពៃណីគឺគ្រាន់តែដឹង ហើយបើឲ្យចាំជាថ្ងៃខែរបៀបរបបគឺសូមទោស ។

សិត្យា បានបញ្ជាក់ថា "ការអនុវត្តនិងការអានត្រឹមតែឯកសារគឺអង្គចងចាំមនុស្សម្នាក់ៗពិតជាពិបាកណាស់ ប៉ុន្តែបើធ្លាប់បានអាន ហើយនៅពេលដែលត្រូវការ គឺយើងអាចដឹងថាឯកសារនោះព្រឹត្តិការណ៍នោះ ប្រវត្តិនៃពិធីបុណ្យនេះគឺមាននៅកន្លែងណា ហើយយើងអាចរកបានភ្លាមៗ ប៉ុន្តែបើនឹកភ្លាមៗ គឺមិនអាចទេ "។

លីន ចំរើន ជាយុវជនវ័យ១៨ឆ្នាំមួយរូបបានអះអាងថា ជាការពិតបុណ្យប្រពៃណីជាតិមួយចំនួនប្អូនពិតជាមិនដឹងមែន ប៉ុន្តែប្អូនក៏ស្គាល់នូវអត្ថន័យនិងចងចាំនូវបុណ្យមួយចំនួនដែរ ដូចជា បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ បុណ្យភ្ជុំបិណ្ឌ បុណ្យកឋិនទាន បុណ្យអុំទូកជាដើម ។ល។

ចំរើន បានបញ្ជាក់ឲ្យដឹងថា "ជាទូទៅសម្រាប់អត្ថន័យពិធីបុណ្យផ្សេងៗទៀតក៏មិនមែនថា យុវជនហើយនិងខ្ញុំមិនដឹងនោះទេ គ្រាន់តែមិនបានយកចិត្តទុកដាក់ ប៉ុន្តែប្រសិនជាយើងយកចិត្តទុកដាក់នោះយើងនឹងអាចដឹងបាន" ។

ចំរើនបានបន្តទៀតថា នៅពេលនេះនៅកម្ពុជាមានបុណ្យបរទេសជាច្រើនដែលបានហូរចូលមកបន្ថែមលើបុណ្យផ្សេងៗដែលមានដូចជា បុណ្យឪពុកជាដើម ប៉ុន្តែយុវជនគឺមិនមែនចេះតែចងចាំទាំងអស់នោះទេ ទាល់តែបានប្រឡូកម្តងហើយម្តងទៀត ដូចជាបុណ្យនៃសេចក្តីស្រឡាញ់ បុណ្យណូអែល ជាដើម ទើបគេអាចចងចាំបាន។

*ដោយអរិយបុត្រ*

# ព្រះសហគមន៍មានអំណរសប្បាយទទួល២២៥នាក់ជាគ្រីស្តបរិស័ទ



*លោកបូជាចារ្យវ៉ូសាំង សេរ៉ាល់ ធ្វើពិធីជ្រមុជទឹកជូនបេក្ខជន នៅព្រះសហគមន៍កោះរការ។ រូបថតដោយ ស្រីម៉ាច*

ព្រះសហគមន៍កាតូលិកនៅកម្ពុជាក្នុងបីភូមិភាគបានរៀបចំពិធីជ្រមុជទឹកដល់មនុស្សពេញវ័យប្រមាណ២០០នាក់ក្នុងឱកាសបុណ្យព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿងក្នុងខែមីនាកន្លងទៅ។

យុវជនស្រ៊ុន ពន្លឺ វ័យ២២ឆ្នាំ ទទួលពិធីជ្រមុជទឹកនៅព្រះសហគមន៍កោះរការ បាននិយាយថា "វាជាពេលមួយដែលខ្ញុំទន្ទឹងរង់ចាំជាយូរមកហើយតាំងពីរៀនអប់រំជំនឿ ធ្វើឲ្យខ្ញុំកាន់តែមានទំនុកចិត្ត និងមានជំនឿកាន់តែរឹងមាំឡើងទៀត"។ យុវជនរូបនេះបានបន្តថា បន្ទាប់ពីក្លាយជាគ្រីស្តបរិស័ទ លោកនិងព្យាយាមជួយរាល់សកម្មភាពនៅក្នុងព្រះសហគមន៍ ពង្រឹងជំនឿរបស់ខ្លួនដោយធ្វើការអធិដ្ឋាន និងជួយពន្យល់ណែនាំអ្នកដែលមានបំណងចង់ស្គាល់អំពីព្រះយេស៊ូ ទោះបីជាមិនបានច្រើនយ៉ាងហោចណាស់ក៏បានចូលរួមចំណែកដោយចិត្តស្មោះជាមួយព្រះសហគមន៍កាតូលិកដែរ។

យុវនារី ង៉ា វិផស្ស អាយុ២៣ឆ្នាំ បានទទួលពិធីជ្រមុជទឹកនៅព្រះសហគមន៍បាត់ដំបង បាននិយាយថា "ខ្ញុំមានអារម្មណ៍ថាសប្បាយចិត្ត និងរំភើបអស់ពីចិត្ត ហើយក៏អរគុណអ្នកគ្រូនិងបងស្រីដែលបានលើកទឹកចិត្ត និងបង្រៀន។ ខ្ញុំនឹងកែប្រែជីវិតរស់នៅចាស់ និងជួយព្រះសហគមន៍ឲ្យបានច្រើន ជាពិសេសអ្នកដែលមានជំនឿទន់ខ្សោយ។ បើខ្ញុំមានសមត្ថភាព ខ្ញុំនឹងបង្រៀនបន្ត(ជំនឿ)"។

ពិធីជ្រមុជទឹកផ្តល់ឲ្យគ្រីស្តបរិស័ទមានជីវិតថ្មីក្នុងអង្គព្រះគ្រីស្ត។ តាមព្រះហឫទ័យរបស់ព្រះអម្ចាស់ យើងត្រូវតែទទួលពិធីជ្រមុជទឹក ដើម្បីទទួលការសង្គ្រោះ ដូចជាព្រះសហគមន៍ផ្ទាល់ដែលនាំឲ្យយើងទទួលពិធីជ្រមុជទឹក។ *(លិខិត១២៧៧)*

លោក សេក ប៊ុនណា ជាបេក្ខជនជ្រមុជទឹកនៅភ្នំពេញថ្មីបានឲ្យដឹងថា "ក្រោយពីខ្ញុំបានទទួលការអប់រំជំនឿទើបខ្ញុំដឹងថា រាល់ព្រះបន្ទូលទាំងអស់គឺជាសេចក្តីពិត ហើយត្រូវនឹងជីវិតដែលខ្ញុំរស់នៅសព្វថ្ងៃ និងធ្វើឲ្យខ្ញុំដឹងច្បាស់ថាព្រះយេស៊ូគ្រីស្តជាអង្គព្រះសង្គ្រោះ។ អ្វីដែលដក់ជាប់ក្នុងចិត្ត គឺខ្ញុំបានយកព្រះសហគមន៍ជាទីពឹង ព្រះបន្ទូលជាទីពឹង និងយកព្រះគ្រីស្តជាទីពឹង ដោយសុខចិត្តផ្ញើជីវិត និងដើរតាមព្រះយេស៊ូ"។

លោកអភិបាលអូលីវីយេ ឆ្មឹតអឺស្លែរ នៃភូមិភាគភ្នំពេញបានមានប្រសាសន៍ថា សូមឲ្យគ្រីស្តបរិស័ទចេះបម្រើដូចព្រះយេស៊ូ និងចេះទទួលស្វាគមន៍អ្នកក្រីក្រ ជនពិការ កុមារកំព្រា អ្នកសង្គមបោះបង់ និងសម្រាប់មនុស្សទាំងអស់ដើម្បីឲ្យយើងទៅជាពន្លឺរបស់ព្រះគ្រីស្ត។ លោកអភិបាលបន្តថា ព្រះយេស៊ូយាងមកដើម្បីរំដោះយើងឲ្យរួចពីមន្ទីរឃុំឃាំងនៃដួងចិត្តរបស់យើង និងព្យាបាលរូបកាយយើងដែលមានរបួសយ៉ាងជ្រៅ។

លោកអភិបាលហ្វីការេដូ អេនរីគេនៃភូមិភាគបាត់ដំបងបានមានប្រសាសន៍ថា "យើងត្រូវរិះគិតពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ហើយសូមឲ្យយើងមានធម៌មេត្តាករុណាដូចព្រះបិតា និងសូមឲ្យយើងមានបេះដូងដូចព្រះជាម្ចាស់ ដើម្បីឈ្នះសេចក្តីស្លាប់និងអំពើឃោឃៅ"។

ក្នុងឆ្នាំនេះព្រះសហគមន៍កាតូលិកមានគ្រីស្តបរិស័ទថ្មីសរុបចំនួន ២២៥នាក់ ដែលក្នុងនោះមានភូមិភាគភ្នំពេញចំនួន១១១នាក់ ភូមិភាគបាត់ដំបងចំនួន៦៧នាក់ និងភូមិភាគកំពង់ចាមមានចំនួន៤៧នាក់។ ដោយCSC

# ពិធីឆ្លងចេតីយ និងរូបសំណាកលោកទ្រឿង ប៊ូយៀប



*លោកអភិបាលអូលីវីយេ កាត់ខ្សែបូសម្ពោធទីសក្ការៈរបស់លោកប៊ូយៀប។ សុធីរិទ្ធ*

គ្រីស្តបរិស័ទប្រមាណជាងបីពាន់នាក់បានមកចូលរួមក្នុងពិធីឆ្លងចេតីយ និងរូបសំណាករបស់លោកបូជាចារ្យ ហ្វ្រង់ស្វ័រសាវីយ៉េ ទ្រឿង ប៊ូយៀប នៅព្រះសហគមន៍ផ្លូវត្រី ក្រោមអធិបតីរបស់លោកអូលីវីយេ ឆ្មឹតអឺស្លែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រួមជាមួយលោកបូជាចារ្យជាច្រើនអង្គទៀត នាថ្ងៃទី១២មីនានេះ។

នៅក្នុងពិធីនោះ លោកអភិបាលបានមានប្រសាសន៍ទៅកាន់គ្រីស្តបរិស័ទឲ្យហ៊ានប្រកាសជំនឿរបស់ខ្លួន ដោយចូលទៅក្នុងសង្គមធ្វើជាសាក្សីអំពីវត្តមានរបស់ព្រះជាម្ចាស់នៅលើទឹកដីរបស់ខ្លួនកំពុងរស់នៅដោយយកគំរូរបស់លោកបូជាចារ្យប៊ូយៀប និងមរណសាក្សីនៅប្រទេសនានា ជាពិសេសនៅកម្ពុជាដែលហ៊ានប្រកាសដំណឹងល្អ និង បូជាជីវិតសម្រាប់បងប្អូនក្រីក្រ។

លោកអភិបាលមានប្រសាសន៍ទៀតថា ព្រះយេស៊ូបានឲ្យគ្រីស្តបរិស័ទហ៊ានលះបង់ខ្លួនដើម្បីទទួលបានជីវិត ដោយមិនលោភលន់ចង់បានទ្រព្យសម្បត្តិ។ លោកអភិបាល "យើងអាចរកស៊ីតាមសេចក្តីត្រូវការរបស់យើង តែយើងក៏ត្រូវចេះចែករំលែកជាមួយអ្នកអ្នកដទៃ ជាពិសេសអ្នកក្រីក្រលំបាកដែលមានចំនួនច្រើននៅលើទឹកដីកម្ពុជានាពេលបច្ចុប្បន្ន"។ លោកអភិបាលសូមឲ្យគ្រីស្តបរិស័ទចេះបើកចិត្តឲ្យទូលំទូលាយដោយធ្វើសកម្មភាពធម៌មេត្តាករុណាទាំងផ្លូវកាយ និងផ្លូវវិញ្ញាណដើម្បីឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់បានមកលើផែនដី។

ក្នុងកម្មវិធីនោះផងដែរ ក៏មានកុមារចំនួន៤០នាក់ទទួលព្រះកាយលើកដំបូងផងដែរ។

លោកបូជាចារ្យ ហ្វ្រង់ស្វ័រសាវីយ៉េ ទ្រឿង ប៊ូយៀប ជាជនជាតិវៀតណាមធ្លាប់បានសិក្សា នៅទេវវិទ្យាល័យនៅកម្ពុជា។ ក្រោយពីលោកបានតែងតាំងជាបូជាចារ្យកាតូលិកក្នុងភូមិភាគភ្នំពេញ លោកបានមកបំពេញបេសកកម្មបម្រើព្រះសហគមន៍ផ្លូវត្រី នៅក្នុងប្រទេសកម្ពុជា។ ក្រោយមកលោកបានត្រឡប់ទៅប្រទេសវៀតណាម ដើម្បីប្រើព្រះសហគមន៍នៅទីនោះ។ ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញកាលពីដើមលាតសន្ធឹងពីប្រទេសកម្ពុជាទៅដល់ទឹកដីកម្ពុជាក្រោម។

លោកប៊ូយៀប កើតនៅថ្ងៃទី១មករា ១៨៩៧។ នៅថ្ងៃទី១២ មីនា ១៩៤៦ លោកបានទទួលមរណភាពដោយលោកបានប្តូរជីវិតរបស់ខ្លួនគឺសុំស្លាប់ជំនួសគ្រីស្តបរិស័ទនិងប្រជាជនដើម្បីឲ្យពួកគេបានរួចជីវិតនៅក្នុងសម័យសង្គ្រាមនៅប្រទេសវៀតណាម៕

*ដោយ កញ្ញា*

# ព្រះសហគមន៍ រួមចំណែកបណ្តុះបណ្តាលធនធានមនុស្ស

*វិស័យអប់រំគឺជាវិស័យអាទិភាពមួយ នៅក្នុងប្រទេសកម្ពុជា ហើយវិស័យនេះ ត្រូវបានគេអះអាងថា គឺជាប្រភពនៃការ អភិវឌ្ឍន៍ដែលមិនអាចខ្វះបាន ដូច្នេះ ហើយវិស័យនេះមានអង្គការក្រៅរដ្ឋាភិបាល ស្ថាប័នហិរញ្ញវត្ថុធំៗបានធ្វើសកម្មភាពនៅក្នុងនោះក៏មានព្រះសហគមន៍ កាតូលិកមួយផងដែរ។ ដើម្បីឲ្យមិត្តអ្នក អានអាចជ្រាបថា តើសព្វថ្ងៃនេះព្រះសហគមន៍កាតូលិកនៅកម្ពុជា ជាពិសេស គឺព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានរួមចំណែកអ្វីខ្លះនៅក្នុងសង្គម អ្នក នាំសារសូមអនុញ្ញាតជួបជាមួយនឹង អ្នកស្រីឡៃមករាជាប្រធានការិយាល័យ ផ្នែកសិក្សាអប់រំនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញដូចតទៅ ៖*



*អ្នកស្រីឡៃ មករា ប្រធានការិយាល័យផ្នែកសិក្សាអប់រំរបស់ព្រះសហគមន៍*

**អ្នកនាំសារ៖** តើការិយាល័យអប់រំ របស់ព្រះសហគមន៍កាតូលិកមួយនេះ បានចាប់ផ្តើមសកម្មភាពតាំងពីពេល ណាមក ?

**អ្នកស្រី ឡៃ មករា ៖** សម្រាប់ការិយាល័យនេះ គឺបានដំណើរការនៅក្នុង ប្រទេសកម្ពុជា គឺតាំងពីឆ្នាំ២០១៤ មក ដល់ពេលបច្ចុប្បន្ន ប៉ុន្តែមិនមែនមាន ន័យថា ព្រះសហគមន៍កាតូលិកនៅកម្ពុជា ជាពិសេសគឺភូមិភាគភ្នំពេញទើបតែ ចាប់ផ្តើមសកម្មភាពនេះនោះទេ។ កិច្ច ការអប់រំនេះ គឺបានដំណើរការជាយូរមក ហើយ ហើយក៏ជាវិស័យអាទិភាពមួយ របស់ព្រះសហគមន៍កាតូលិកផងដែរ។ ការិយាល័យនេះ គឺបច្ចុប្បន្នកំពុងតែគ្រប់ គ្រងនៅលើគម្រោងអប់រំមួយចំនួនរបស់ ព្រះសហគមន៍។ នៅក្នុងនោះមានដូច ជាគម្រោងសាលាមត្តេយ្យសិក្សាសាលា បឋមសិក្សា វិទ្យាល័យចំណោះទូទៅ និង បច្ចេកទេសឯកជនសន្តហ្វ្រង់ស័រ វិទ្យា ស្ថានសន្តប៉ូល មណ្ឌលវប្បធម៌និងភាសា បរទេសខេត្តកំពត និងកម្មវិធីអានសៀវភៅក្រៅប្រព័ន្ធ។

**អ្នកនាំសារ៖** តើសកម្មភាពរបស់ ការិយាល័យអប់រំព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញបានធ្វើនេះ មានទស្សន វិស័យយ៉ាងណាខ្លះ ?

**អ្នកស្រី ឡៃ មករា៖** ទស្សនវិស័យ និងគោលបំណងជាចម្បងរបស់ការិយាល័យនេះគឺចង់ឲ្យកុមារនិងយុវជនមាន ចំណេះដឹងជ្រៅជ្រះ ចាប់តាំងពីកម្រិត មត្តេយ្យសិក្សារហូតបញ្ចប់ថ្នាក់ទី១២ និងការអប់រំកម្រិតឧត្តមសិក្សា។ រហូត មកដល់ពេលនេះ យើងបានខិតខំកសាង និងផ្តល់ការអប់រំកម្រិតមត្តេយ្យសិក្សានេះ ចំនួន២៥កន្លែង។ ហើយនៅក្នុងនោះ យើងបានចែងចែកជា៥តំបន់។

**អ្នកនាំសារ៖** ចុះកម្មវិធីចំណេះទូទៅ វិញ តើព្រះសហគមន៍មានសកម្មភាពអ្វី ខ្លះដែរ ?

**អ្នកស្រីឡៃមករា៖** យើងមានសាលា បឋមសិក្សាសម្រាប់សហគមន៍វៀតណាមចំនួន១៤កន្លែង ដូចជា កោះនរា តួតាំង ផ្លូវត្រី ចំប៉ា ទួលក្រសាំង។ល។ មិនតែប៉ុណ្ណោះ គឺព្រះសហគមន៍ក៏មាន កម្មវិធីអប់រំអក្ខរកម្មនៅ៥កន្លែង។ ចំពោះ គម្រោងនៅ វិទ្យាល័យចំណេះទូទៅនិង បច្ចេកទេសទូទៅឯកជនសន្តហ្វ្រង់ស័រ នៅខេត្តតាកែវ គឺមានកម្មវិធីចំណេះទូទៅពីថ្នាក់ទី៧ដល់ថ្នាក់ទី១២ ហើយ កាលពីឆ្នាំសិក្សា២០១៥និង២០១៦ គឺ យើងបានបង្កើតនៅសាលាបច្ចេកទេស កសិកម្មពីថ្នាក់ទី១០ដល់ទី១២ ដែល មានចំនួន២២ម៉ោងនៅក្នុងមួយសប្តាហ៍ ហើយនៅពេលបច្ចប់ការសិក្សា បណ្តា ប្អូនៗនិស្សិត គឺអាចមានសញ្ញប័ត្រដែល ទទួលស្គាល់អំពីជំនាញកសិកម្ម ដែល អាចឲ្យប្អូនអាចរកការងារធ្វើបាន ឬអាច ប្រកបរបរទទួលទាន ឬបន្តការសិក្សា ជំនាញដែលប្អូនចង់។ រហូតមកដល់ បច្ចុប្បន្ននេះ គុណភាពនៃការបណ្តុះ បណ្តាលគឺល្អប្រសើរដោយលទ្ធផលប្រឡងគឺជាប់ជាង៩០ភាគរយឡើង ។

**អ្នកនាំសារ៖** ចុះការអប់រំកម្រិតឧត្តម សិក្សា និង មណ្ឌលវប្បធម៌វិញ ?

**អ្នកស្រី ឡៃ មករា៖** សម្រាប់ការអប់រំ នៅឧត្តមសិក្សា គឺយើងមានវិទ្យាស្ថាន សន្តប៉ូល ។នេះគឺជាស្ថាប័នឧត្តមសិក្សា មួយដែលមានមហាវិទ្យាល័យក្សេត្រ សាស្ត្រ ព័ត៌មានវិទ្យា គ្រប់គ្រងទេសចរណ៍ មហាវិទ្យាល័យអក្សរសាស្ត្រអង់គ្លេស និងសង្គមកិច្ចផងដែរ។ ហើយនៅក្នុង ឆ្នាំ២០១៥ និង ២០១៦ នេះវិទ្យាស្ថាន គ្រោងនឹងបើកថ្នាក់បរិញ្ញប័ត្ររងដែល មាន៧មុខជំនាញថែមទៀត ។ សម្រាប់ មណ្ឌលវប្បធម៌និងភាសាបរទេសខេត្ត កំពតដែលបង្កើតឡើងនាឆ្នាំ២០០៧ គឺមានកម្មវិធីបណ្តុះបណ្តាលភាសាអង់ គ្លេសក្រៅម៉ោង កុំព្យូទ័រនិងកម្មវិធីសិល្បៈ របាំនិងគំនូរ។ល។

**អ្នកនាំសារ៖** តើកម្មវិធីអ្វីដែលថ្មីបំផុតដែលការិយាល័យអប់រំព្រះសហគមន៍ កាតូលិកបានដាក់ឲ្យអនុវត្តដើម្បីចូលរួម កម្មវិធីអប់រំនៅកម្ពុជា ?

**អ្នកស្រី ឡៃ មករា៖** កម្មវិធីថ្មីគឺកម្មវិធី មតេយ្យសិក្សាម៉ុងតេសេរី។ កម្មវិធីនេះ ជាកម្មវិធីអប់រំកុមារថ្មីបំផុត នៅក្នុងប្រទេសកម្ពុជា។ ការចែករំលែកមួយនេះ ព្រះសហគមន៍នាំយកនូវបច្ចេកទេស អប់រំបែបថ្មីមកតំបន់ជនបទនៅកម្ពុជា ជាក់ស្តែងនៅមត្តេយ្យសិក្សាចំការទៀង គឺយើងមានសម្ភារបង្រៀនជាច្រើន ជា កម្មវិធីដែលអ្នកគ្រូ អ្នកសម្របសម្រួល រវល់មែនទែន ដើម្បីផ្តល់ការសិក្សាស្វែង យល់ដល់កុមារ។

ក្រៅពីសកម្មភាពទាំងនេះ ព្រះសហគមន៍កាតូលិកនៅកម្ពុជា ក៏មានចូលរួម ចំណែកបណ្តុះបណ្តាលបច្ចេកទេសពហុ ជំនាញជាច្រើន តាមរយៈសាលាដុនបូស្កូ។ សាលានេះ កំពុងតែរួមចំណែក នៅក្នុងការកសាងអនាគត ក្មេងកំព្រា ក្រីក្រ និងយុវជនជាច្រើនឲ្យមានអនាគតភ្លឺស្វាងតាមរយៈកម្មវិធីបណ្តុះបណ្តាល ជំនាញលេខាធិការ ជំនាញផ្នែកមេកានិច អគ្គិសនី ជាដើម។

*ដោយ ឡុង សម្ផស្ស*

# សិក្ខាសាលាស្តីអំពីការសម្តែងធម៌មេត្តាករុណា

ព្រះវិហារព្រះត្រៃឯកគិរីវង់ ដែលស្ថិតនៅក្នុងភូមិ ព្រៃដើង ឃុំគោកព្រេច ស្រុកគិរីវង់ ខេត្តតាកែវ កាលពី ថ្ងៃទី១៩ ខែមីនា បានធ្វើសិក្ខាសាលាមួយដែលស្តីពី ភាពក្រីក្រ និងបានរិះគិតពីបញ្ហានិងមូលហេតុនៃភាព ក្រីក្រ ដូចជា កត្តាក្រីក្រផ្នែកសម្ភារ កត្តាសីលធម៌ និង កត្តាខាងផ្លូវវិញ្ញាណ ដែលរៀបចំឡើងដោយក្រុមដឹក នាំយុវជននៃព្រះសហគមន៍គីរីវង់និងមានគ្រីស្តបរិស័ទ ចូលរួមជិត២០នាក់។

សិក្ខាសាលានេះត្រូវបានចែកជាក្រុមតូចៗមាន ក្រុម ស្បៀងអាហារ ក្រុមសួរសុខទុក្ខដល់អ្នកជម្ងឺ និង ក្រុម ចែករំលែកសម្ភារទៅដល់អ្នកដែលមានភាពខ្វះខាត ហើយដែលកំពុងតែជួបការលំបាក។

អ្នកស្រី តែប ជាអ្នកជម្ងឺដែលរស់នៅក្នុងភូមិព្រៃដើង បាននិយាយថា"នៅពេលដែលបងប្អូនបានទៅសួរសុខ ទុក្ខខ្ញុំ គឺឲ្យនាងខ្ញុំពិតជាមានកម្លាំងចិត្តជាងមុន និង មានអំណរសប្បាយជាខ្លាំង ធ្វើអោយខ្ញុំមានអារម្មណ៍ ថាធូរស្បើយជាងមុន និង មានអារម្មណ៍ថាបងប្អូនមិន បានរើសអើងឬក៏ស្អប់ខ្ពើមខ្ញុំទេ ហើយខ្ញុំពិតជារំភើប ខ្លាំងបំផុត"។

លោកបូជាចារ្យអាំាងហ្គោ សាប៉ាតា ហ្វេរណាន់ដូ ទទួលខុសត្រូវព្រះសហគមន៍កាតូលិកព្រះត្រៃឯក( គីរីវង់ )បានមានប្រសាសន៍ថា សកម្មភាពសួរសុខទុក្ខដល់ អ្នកជម្ងឺ អ្នកក្រីក្របែបនេះគឺជាសកម្មភាពមួយជួយ លើកទឹកចិត្ត និងផ្តល់ជាកំលាំងចិត្តដល់ពួកគាត់។ លោកបន្តថា យើងមិនត្រូវការអ្វីដែលធំដុំប៉ុន្មានទេ អ្វី ដែលសំខាន់ជាងគេគឺផ្តល់នូវភាពកក់ក្តៅ លើកទឹកចិត្ត ផ្តល់កម្លាំងចិត្ត និងវត្តមានរបស់ពួកយើងទៅសួរសុខ ទុក្ខត្រឹមតែ៥នាទីទៅ១០នាទីប៉ុណ្ណោះទេ តែយើងអាច ផ្តលនូវភាពកក់ក្តៅ និងអំណរសប្បាយ សេចក្តីសង្ឃឹម និងសេចក្តីស្រលាញ់ចំពោះគាត់ ព្រោះយើងទទួលមក ពីព្រះជាម្ចាស់ ហេតុនេះហើយយើងមិនត្រូវភ្លេចព្រះ ជាម្ចាស់បានឡើយ។

*ដោយ សុខ ណាន*

# វាចាពលរដ្ឋខ្មែរប៉ុន្មានរូបៈ គ្មាននរណាចង់ទៅធ្វើការនៅក្រៅស្រុកមិនស្គាល់គេមិនស្គាល់ឯងនោះទេ



*ប្រជាជនកម្ពុជាធ្វើការងារជាកម្មករសំណង់នៅប្រទេសថៃ រូបថតកាលពីខែកក្កដា ២០១៥។ Photo Supply*

អង្គុយនៅលើម៉ូតូស៊ុយហ្សុយគីវីវ៉ាដែលមានកម្លាំង ១២៥ cc មួយគ្រឿងនៅក្បែរសាលារៀនភាសាកូរ៉េមួយ កន្លែងនៅម្ដុំវត្តទួលសង្កែ បុរសជាពលរដ្ឋខ្មែរប៉ុន្មានរូបបានវាចាថា "មកទល់ពេលនេះទាំងខ្ញុំទាំងគេ គ្មាននរណាចង់ទៅធ្វើការក្រៅស្រុកមិនស្គាល់គេមិនស្គាល់ឯង ឆ្ងាយពីផ្ទះគ្រួសារឡើយ ប៉ុន្តែវាអត់ជម្រើស"។

លោកសេក កក្កដា ជាពលរដ្ឋខ្មែរមួយរូបដែលមានអាយុ៣២ឆ្នាំ បច្ចុប្បន្នជាកម្មករកាត់ដេរ នៅរោងចក្រមួយនៅម្ដុំទួលសង្កែ ហើយក៏ជា ពលរដ្ឋមួយរូបដែលកំពុងតែព្យាយាមសិក្សាភាសាកូរ៉េ នៅក្នុងក្ដីរំពឹងថា នឹងអាចប្រឡងជាប់បានចេញទៅធ្វើការនៅប្រទេសកូរ៉េ នឹងគេនោះបានអះអាងថា ចេញទៅរកការងារធ្វើគឺជាក្ដីរំពឹងមួយ ដែលលោកនិងប្អូនប្រុសបានសង្ឃឹម ដើម្បីជាឱកាសកសាងជីវភាពមួយបានធូធារនឹងគេ។

នៅក្នុងខណៈពេលដែលលោកកំពុងតែខិតខំព្យាយាមរៀនភាសាកូរ៉េ លោកនិងប្អូនប្រុស ចេះតែឮ និងទទួលព័ត៌មាននេះព័ត៌មាននោះទាំងអាក្រក់និងល្អចម្រុះប៉ុន្តែជាតិជាកម្មករដែលគ្មានការសិក្សាជ្រៅជ្រះនឹងគេ រឿងនេះគឺជារឿងក្រោយ។

លោក កក្កដា បានអះអាងថា "ចេះតែឮហើយ ដោយអ្នកខ្លះថាទៅធ្វើការនៅកូរ៉េគេឲ្យបាយតែ មួយពេល ទេ ធ្វើការនៅលើអាគារខ្ពស់ៗ ថៅកែធ្វើបាប កាត់ប្រាក់ខែអី...ជាដើមប៉ុន្តែក៏មានព័ត៌មានល្អច្រើនដែរ គឺបានប្រាក់ខែច្រើន ..."។ល។

លោកបន្តទៀតថា វាចេះតែឮហើយ មិនអត់ទេ ប៉ុន្តែដើម្បីជីវភាពគឺពួកយើងបានសម្រេចចិត្តហើយបើជាប់។ ប្រាក់ខែនៅក្នុងស្រុក និងប្រាក់ខែនៅទីនោះខុសគ្នាឆ្ងាយណាស់ដោយនៅក្នុងស្រុកធ្វើការ៣ទៅ ៥ ឬ ៦ខែ ជួលកាលបានស្មើគេធ្វើមួយខែ ដូច្នេះហើយបានជាខំឯរឿងបារម្ភជារឿងក្រោយ ។

លោកបញ្ជាក់ថា "ជាកម្មករអគ្គិសនីដូចខ្ញុំ ធ្វើការថែមម៉ោងផងអីផង បានត្រឹមតែ ៣៥០ដុល្លារទេ តែខ្ញុំឮថានៅកូរ៉េអាចបានពី៧០០ដុល្លារ ទៅជាង១.០០០ដុល្លារក៏មាន"។

នេះគឺជាក្ដីរំពឹងមួយរបស់លោកកក្កដា ដែលកំពុងតែចង់ក្លាយជាផ្នែកមួយនៃជីវិតជាពលករចំណាកស្រុកមួយរូបដើម្បីភាពប្រសើរឡើងនៃជីវភាពគ្រួសារនៅក្នុងពេលអនាគត។ ដោយឡែកយុវនារីមួយរូបដែកំពុងតែកាន់សម្លរ និង បាយចំអិនស្រាប់មួយថង់ ចេញពីកន្លែងលក់បាយនៅម្ដុំផ្សារឯករាជ្យនៅលើផ្លូវវេងស្រេង ក៏បានអះអាងអំពីការស្វះស្វែងរកការងារនៅក្រៅប្រទេសដែរ ។

កញ្ញា យិន សម្ផស្ស ជាកម្មការិនីរោងចក្រកាត់ដេរមួយរូបដែលមានអាយុ២៥ឆ្នាំ បាននិយាយថា ការងារជាពលករចំណាកស្រុកក៏ជាប្រភព និងជាក្ដីរំពឹងរបស់កញ្ញាដែរ ដើម្បីរំដោះភាពក្រីក្រដែលគ្រួសារកញ្ញាកំពុងតែជួបប្រទះ។

កញ្ញាបន្តថា សព្វថ្ងៃនេះកញ្ញាមានបងប្អូនដល់ទៅ៧នាក់ សុទ្ធតែពេញហូបចុកពេញរៀនពេញសូត្រ ដូច្នេះធ្វើការត្រឹមកម្មករកាត់ដេរប្រាក់ខែជាង១៦០ ដុល្លារអីថែមម៉ោង បានត្រឹមតែ ២០០ដុល្លារអីនៅក្នុងមួយខែ គឺពិបាកណាស់។

សម្ផស្ស បានឲ្យដឹងថា នៅពេលនេះកញ្ញានិងមិត្តភ័ក្រ គឺកំពុងតែព្យាយាមដាក់ពាក្យទៅកូរ៉េ ម៉ាឡេស៊ីអីតាមក្រុមហ៊ុនមួយដែលកញ្ញាមិនចាំឈ្មោះ ដោយគេប្រាប់ថា ប្រាក់ខែគឺអាចបានពី ៤០០ ដុល្លារ ទៅ ១.០០០ ដុល្លារ។

កញ្ញាបាននិយាយបន្តថា "ខ្ញុំដឹងថាការសម្រេចចិត្តនេះជាការប្រថុយប្រថានដោយសារតែឮថា នៅម៉ាឡេស៊ីថៅកែចាប់រំលោភ បង្អត់បាយជាដើម ប៉ុន្តែអាក្រក់ដូចខ្ញុំ មាឌរាងធំ ធាត់ដូចខ្ញុំ ប្រហែលមិនអីទេ"។

កញ្ញា បានបញ្ជាក់ទៀតថា "បើមិនប្រថុយមិនបានទេ ប្រាក់ខែត្រឹម ២០០ ដុល្លារ អីគ្រួសារស្ទុះវាមិនរួចទេ"។

កញ្ញា រ៉េត ហៀង ដែលកំពុងតែដើរបណ្ដើរគ្នា ជាមួយនឹង សម្ផស្សក៏បានលូកមាត់ថា "ក្រវាមិនឈ្នះទាល់ទេ ដូច្នេះក៏ចេញតែសាកល្បងទៅ"។

កញ្ញា បានបន្តថា បើទោះបីជាពលករចំណាកស្រុកជាក្ដីរំពឹងរបស់ពួកនាងនៅក្នុងការកែប្រែជីវភាព ប៉ុន្តែបទពិសោធន៍តាមរយៈការស្ដាប់ព័ត៌មាន គឺបានបណ្ដាលឲ្យកញ្ញាទាំងពីរនេះព្យាយាមប្រមូលព័ត៌មានលំអិតផ្សេងៗពីក្រុមហ៊ុន ដែលនាងបានព្យាយាមទៅស្វែងរកការងារនោះ។

តាមរបាយការណ៍របស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ពេលនេះកម្ពុជាមានក្រុមហ៊ុននាំពលករចេញទៅក្រៅប្រទេសប្រមាណជា៦០ក្រុមហ៊ុន ។

ប្រភពដដែលបានបន្តថា នៅពេលបច្ចុប្បន្ននេះពលករកម្ពុជា កំពុងធ្វើការនៅបរទេសមានចំនួន ៦១៩.៣៥៩ នាក់ ក្នុងនោះប្រទេសថៃចំនួន ៥៣៣.៧០៧ នាក់ ប្រទេសម៉ាឡេស៊ី ៣៨.៦៣៣ នាក់ ប្រទេសកូរ៉េ ៤៤.៣៣០នាក់ ជប៉ុន ២.២៨៨នាក់ សិង្ហបុរី ៤០១ នាក់។ ក្នុងនោះ ចំណូលជាមធ្យមក្នុងមួយឆ្នាំប្រមាណជាង ១.០០០ លានដុល្លារ។

ក្រៅពីប្រទេសទាំងនេះ នៅក្នុងពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជា កំពុងស្វះស្វែងរកទីផ្សារការងារនេះបន្ថែមទៀត ជាពិសេសនៅមជ្ឈិមបូព៌ា ដាក់ស្ដែងកាលពីខែកុម្ភៈកន្លងទៅនេះ ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានអះអាងថា នៅឆ្នាំ២០១៦នេះ កម្ពុជាអាចនឹងបញ្ជូនពលករទៅធ្វើការនៅប្រទេសអារ៉ាប់ប៊ីសាអូឌីតថែមទៀត ។

ជុំវិញបញ្ហារំលោភបំពានពលករក្រៅប្រទេសដែលមានជាបន្តបន្ទាប់ លោកអ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានមានប្រសាសន៍ថា ក្រសួងនឹងខិតខំទប់ស្កាត់ចំពោះបញ្ហារំលោភបំពានមកលើពលករឱ្យបានជាអតិបរមា។

លោកបានបន្តថា ក្រសួងកំពុងតែខិតខំរៀបចំនូវក្របខ័ណ្ឌបច្ចេកទេសនានា ដើម្បីផ្ដល់ព័ត៌មានឱ្យបានច្បាស់លាស់ជូនដល់ពលករអំពីលក្ខខណ្ឌការងារ ប្រាក់ឈ្នួល និងលក្ខខណ្ឌពាក់ព័ន្ធផ្សេងៗទៀត។

លោកបានបន្តទៀតថាជាងនេះទៀត នៅពេលចេញដំណើរទៅ របស់បងប្អូនក្រសួងក៏មានប្រព័ន្ធតាមដាន ដើម្បីគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងកាត់បន្ថយស្ថានភាពងាយរងគ្រោះរបស់បងប្អូនពលករកម្ពុជា ខណៈពេលដែលមានការចង់ជួញដូរ ឬ កេងប្រវ័ញ្ចកម្លាំងពលកម្មពេលកំពុងបំពេញការងារ។ ល។

*ដោយអរិយបុត្រ*

# កម្ពុជារុះរើគណរដ្ឋមន្ត្រីនៅពាក់កណ្តាលអណត្តិ

បន្ទាប់ពីគណរដ្ឋមន្ត្រីអណត្តិទី៥បានដឹកនាំប្រទេសកម្ពុជាអស់រយៈពេលពាក់កណ្តាលអណត្តិ ប្រមុខរដ្ឋាភិបាលកម្ពុជាបានស្នើសុំទៅរដ្ឋសភាធ្វើការរុះរើគណៈរដ្ឋមន្ត្រីថ្មីមួយ ដែលរដ្ឋសភាអនុម័តកាលពីថ្ងៃទី០៤ ខែ មេសាកន្លងទៅ។

តាមសំណើរដែលចុះហត្ថលេខាដោយសម្តេចតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រីធ្វើសំណើរទៅសម្តេចហេង សំរិន ប្រធានរដ្ឋសភា លោកគាត ឈន់ ដែលមានវ័យជាង៨០ឆ្នាំ ត្រូវបានបញ្ចប់តំណែង ជាឧបនាយករដ្ឋមន្ត្រីប្រចាំការរួមជាមួយនឹង លោកអ៊ឹម ឈុនលឹម ក៏ត្រូវបញ្ចប់តំណែង ជា ទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ហើយលោកហោ ណាំហុង ដែលមានវ័យចំណាស់ដែរនោះ ក៏ត្រូវបានស្នើសុំបញ្ចប់តំណែងជារដ្ឋមន្ត្រីក្រសួងការបរទេស ដោយលោកកាន់ត្រឹមឧបនាយករដ្ឋមន្ត្រី។

តំណែងលោកអ៊ឹម ឈុនលឹម ត្រូវបានជំនួសដោយលោកជា សុផា៉រ៉ា ដែលបច្ចុប្បន្ន ជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ហើយក្រសួងនេះត្រូវជំនួសដោយលោក អ៊ុក រ៉ាប៊ុន បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ហើយក្រសួងនេះត្រូវជំនួសដោយលោកវេង សាខុន បច្ចុប្បន្នជារដ្ឋលេខាធិកាក្រសួងធនធានទឹក និងឧត្តុនិយម។

ក្រសួងការប្រទេស ត្រូវបានជំនួសដោយលោកប្រាក់ សុខុន ដែលបច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ខណៈដែលក្រសួងនេះត្រូវជំនួសដោយលោកត្រាំ អ៊ីវតឹក បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ហើយក្រសួងនេះ ត្រូវបានជំនួសដោយលោក ស៊ុន ចាន់ថុល បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ខណៈដែលក្រសួងពាណិជ្ជកម្មត្រូវបានជំនួស ដោយលោកប៉ាន សូរស័ក្តិ បច្ចុប្បន្នជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មស្រាប់។ ក្រសួងធម្មការ និងកិច្ចការសាសនាត្រូវបានជំនួសដោយលោកហ៊ឹម ឆែម ខណៈលោកមិន ឃិនត្រូវបានតម្លើងឋានៈជាទេសរដ្ឋមន្ត្រី។ ក្រៅពីនេះ រដ្ឋមន្ត្រីទាំងនោះមួយចំនួន ត្រូវបានស្នើតម្លើងឋានៈជាទេសរដ្ឋមន្ត្រី អតីតអភិបាលខេត្តមួយចំនួនក៏បានស្នើជារដ្ឋលេខាធិការ ។ល៕

# កម្ពុជាបន្តស្នើចិនជួយជាច្រើនគម្រោង

រាជធានីភ្នំពេញ៖ សម្តេចតេជោ ហ៊ុន សែន នៅថ្ងៃទី២៣ ខែ មីនា ឆ្នាំ២០១៦ បានជួបពិភាក្សាទ្វេរភាគីជាមួយលោកលី ឃឺឈាង នាយករដ្ឋមន្ត្រីចិន បន្ទាប់ពីចូលរួមកិច្ចប្រជុំកំពូល មេគង្គឡានឆាងលើកទី១។

តាមសេចក្តីរាយការណ៍នៅក្នុងហ្វេសបុក(Facebook) ផ្លូវការរបស់សម្តេចបានឲ្យដឹងថានៅក្នុងកិច្ចប្រជុំនោះសម្តេចតេជោ ក៏បានស្នើឲ្យចិនជួយពិនិត្យនិងសម្រេចឲ្យបានឆាប់លើគម្រោងសាងសង់ពហុកីឡាដ្ឋានមរតកតេជោ និងគម្រោងសាងសង់មន្ទីរពេទ្យចំនួន2ព្រមទាំងវិទ្យាស្ថានធនធានទឹក ដែលមិត្តចិនបានសម្រេចរួចហើយ។

ទន្ទឹមនឹងនោះ សម្តេចតេជោ ហ៊ុន សែន បានស្នើសុំឲ្យមិត្តចិនជួយក្នុងការសាងសង់ផ្លូវល្បឿនលឿន (Express Way) ពីភ្នំពេញទៅក្រុងព្រះសីហនុ និងព្រលានយន្តហោះថ្មីនៅខេត្ត សៀមរាប និងក៏បានស្នើឲ្យចិនជួយផ្តល់លទ្ធភាពឲ្យបានទូលាយក្នុងការនាំផលិតផលកសិកម្ម ជាពិសេសអង្ករពីកម្ពុជាមកប្រទេសចិន។

នាឱកាសនោះ លោកនាយករដ្ឋមន្ត្រីចិនបានសន្យានឹងជួយគៀងគរជំរុញអ្នកវិនិយោគទុនចិនឲ្យទៅបណ្តាក់ទុននៅកម្ពុជា រួមទាំងការតម្លើងរោងចក្រប្រកបដោយបច្ចេកទេសខ្ពស់ ដើម្បីកម្ពុជាមានលទ្ធភាពផលិតតាមស្តង់ដារ និងគុណភាពអន្តរជាតិសម្រាប់នាំចេញទៅកាន់ប្រទេសចិន និងបណ្តាប្រទេសនានាក្នុងពិភពលោកបាន៕

# សម្តេចប៉ាប៖ ក្តីករុណា និងក្តីស្រលាញ់ប្រឆាំងនឹងអំពើបាប

ក្នុងថ្ងៃបុណ្យចម្លងសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា អំពើបាបគឺអាចនឹងរម្ងាប់បាន ដោយសារតែសេចក្តីករុណា និងសេចក្តីស្រលាញ់ ។

យោងទៅតាមការផ្សាយរបស់វិទ្យុវាទីកង់ បានឲ្យដឹងថាកាលពីឱកាសបុណ្យចម្លង សម្តេចប៉ាប ហ្វ្រង់ស៊ីសបានថ្លែងថា ជីវិតគឺត្រូវបានប្រឈមដោយអំពើបាប ប៉ុន្តែសេចក្តីមេត្តាករុណានិងសេចក្តីស្រលាញ់ គឺជា អ្នកដែលប្រឆាំងនឹងអំពើបាបទាំងនេះ ហើយអាចមានប្រសិទ្ធិភាពខ្ពស់នៅក្នុងការរម្ងាប់នូវអំពើទាំងនេះផង។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា ជំនឿ និងសេចក្តីសង្ឃឹម គឺជាអំណោយទានពីព្រះជា-ម្ចាស់ ដូច្នេះយើងត្រូវតែទូលអង្វរព្រះជាម្ចាស់ឲ្យនាំមកយើងនូវជំនឿ និងក្តីសង្ឃឹមនេះ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា មនុស្សពិតជាមានតម្រូវការជាច្រើនតាមអារម្មណ៍និងសកម្មភាពមួយចំនួន ប៉ុន្តែជាគ្រីស្តបរិស័ទ គឺត្រូវតែដើរទៅតាមផ្លូវនៃសេចក្តីមេត្តាករុណា និងក្តីសង្ឃឹម។ សេចក្តីដ៏ចាំបាច់ទាំងនេះ គឺជាប្រភពដែលនាំឲ្យជីវិតប្រកបដោយភាពស្រស់ស្រាយនិងកុសល។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងបន្តទៀតថា មេត្តាករុណា និងក្តីសង្ឃឹមនេះ គឺប្រភពដែលនាំមកនូវទស្សនវិស័យថ្មី និងបេះដូងថ្មីប្រកបដោយភាពកក់ក្តៅមួយនៅក្នុងជីវិត ហើយជៀសឆ្ងាយពីពិភពនៃភាពខ្មៅងងឹត៕

# សម្តេចប៉ាបបង្កើតគណនីបណ្តាញសង្គមថ្មី Instagram

វិទ្យុវាទីកង់បានធ្វើសេចក្តីរាយការណ៍ថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៦ កន្លងទៅនេះបានបង្កើតគណនីបណ្តាញសង្គមមួយថ្មី។

ប្រភពដដែលបានរាយការណ៍ថា បណ្តាញសង្គមដែលសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបានបង្កើត ដើម្បីទំនាក់ទំនងក៏ដូចជា ប្រកាសដំណឹងល្អនោះ គឺជាបណ្តាញសង្គមអ៊ីនស្តាហ្គ្រាម (Instagram)។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបានប្រកាសថា "ខ្ញុំនៅពេលនេះគឺជាអ្នកកំពុងតែចាប់ផ្តើមថ្មីនៅលើបណ្តាញអ៊ីនស្តាហ្គ្រាម ដើម្បីធ្វើដំណើរតាមផ្លូវនៃមេត្តាករុណា និងការលើកតម្កើងព្រះជាម្ចាស់ ។

ប្រភពដដែលបានអះអាងថា បណ្តាញសង្គមថ្មីនេះគឺសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបង្កើតដោយខ្លួនសម្តេចផ្ទាល់ និងប្រើប្រាស់ដោយសម្តេចផ្ទាល់ បានចុះឈ្មោះថា ហ្វ្រង់ស៊ីស្កូស្កាស់ (Franciscus)។ គណនីបណ្តាញសង្គម នេះ គឺ បានចុះឈ្មោះ នៅនិវេសនដ្ឋានសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ នៅវិមានខាសាសាន់តាម៉ាតា។

ប្រភពដដែលបានអះអាងថា សម្តេចប៉ាបក៏បានបង្ហោះនូវរូបភាពដំបូងរបស់ខ្លួនលោកនៅក្នុងពេលសម្តេចប៉ាបអធិដ្ឋាន ។

អ៊ីនស្តាហ្គ្រាម គឺបណ្តាញសង្គមដែលបង្កើតឡើងនៅឆ្នាំ២០១០។ បច្ចុប្បន្នមានអ្នកដែលចុះឈ្មោះប្រើប្រាស់ប្រមាណជា៤០០លាននាក់នៅពាសពេញពិភពលោក។ ដោយឡែកបច្ចុប្បន្ននេះ សម្តេចប៉ាបដែលក៏បានប្រើទ្វីតធ័រ (twitter)ដែរ គឺមានអ្នកគាំទ្រសម្តេចប្រមាណជា២៦លាននាក់៕

# វាចាអ្នកបង់ពន្ធប្រាក់ខែ "

អ្នកដែលបានបង់ពន្ធប្រាក់បៀវត្សរ៍ប្រចាំខែមួយចំនួនចាប់ផ្តើមមានចម្ងល់អំពីប្រាក់ពន្ធដែលពួកគេ បានបង់ជារៀងរាល់ខែ ប៉ុន្តែពួកគេបែជាមិនមានអត្ថប្រយោជន៍ឬក៏ការគាំពារណាមួយទាល់តែសោះ ដែលពួកគេបានទទួលពីរដ្ឋនៅក្នុងនាមពួកគេជាម្ចាស់ប្រាក់មួយចំណែកដែលពួកគេបានរួមចំណែកបង់ពន្ធជូនប្រទេសជាតិ។

លោក គី សុខចំរើន ជាបុគ្គលិកក្រុមហ៊ុនមួយអះអាងពីតុកាហ្វេមួយកន្លែងនៅម្តុំទូតចិនថា សព្វថ្ងៃនេះលោកជាប់នៅក្នុងកាតព្វកិច្ចត្រូវបង់ពន្ធប្រាក់ខែប្រមាណជា៥ភាគរយនៃប្រាក់បៀវត្សរ៍ប្រចាំខែជារៀងរាល់ខែ ប៉ុន្តែរហូតមកដល់ពេលនេះ លោកមិនបានទទួលអត្ថប្រយោជន៍អ្វីសូម្បីតែបន្តិចពីការបង់ពន្ធនេះ។

លោកបានបន្តទៀតថា "តាំងពីខ្ញុំបានចូលបម្រើការ និងមានប្រាក់បៀវត្សរ៍រហូតមក គឺបានកាត់សម្រាប់ការបង់ពន្ធជារៀងរហូតមក សរុបទៅគិតជាលុយក៏មិនតិចដុល្លារដែរ ប៉ុន្តែខ្ញុំមិនដែលបានទទួលផល ប្រយោជន៍ អ្វី បន្តិច ទាល់តែសោះ ពី ចំណែក នៃ លុយ ដែល ខ្ញុំ បាន ចំណាយកាត់ទុកសម្រាប់បង់ពន្ធជូនរដ្ឋទាំងនេះ"។

លោកបានបន្តទៀតថា "ខ្ញុំ និងកូនប្រពន្ធខ្ញុំឈឺ គឺខ្ញុំនៅត្រូវចេញលុយខ្លួនឯងទាំងអស់ព្យាបាល ខុសពីប្រទេសគេកាលណាគេកាត់ពន្ធ គឺរដ្ឋមានកាតព្វកិច្ចទទួលខុសត្រូវចំណាយផ្សេងៗទាក់ទងនឹងសុខមាលភាពរបស់អ្នកបង់ពន្ធ ប៉ុន្តែនៅស្រុកយើង គឺអត់មានទាល់តែសោះ ដូច្នេះ រដ្ឋគួរតែគិតគូរចំណុចនេះខ្លះ"។

លោកបានបន្តទៀតថា "សម្រាប់មន្ត្រីរាជការ កងប្រដាប់អាវុធ គ្រូបង្រៀនជាដើមនោះ ទោះបីជាគេមិនបានអ្វីតបស្នងប៉ុន្តែនៅពេលចាស់ទៅគេមានប្រាក់ចូលនិវត្តន៍ប្រចាំខែ ប៉ុន្តែសម្រាប់អ្នកផ្សេងរាប់ទាំងខ្ញុំ និងអ្នកដែលធ្វើការនៅក្រុមហ៊ុនឯកជន អង្គការក្រៅរដ្ឋាភិបាលឯទៀតនោះតើបានទទួលអ្វី?"។

លោកចំរើនបានអះអាងថា ជាទូទៅបណ្តាបុគ្គលិកនៅតាមក្រុមហ៊ុនឯកជន និងតាមអង្គការក្រៅរដ្ឋាភិបាល គឺកម្រមានអ្នកណាដែលមិនជាប់កាតព្វកិច្ចបង់ពន្ធលើប្រាក់បៀវត្សរ៍នេះណាស់ គឺម្នាក់ៗតែងតែបង់គ្រប់គ្នា ហើយសំណួរ "តើលុយពន្ធនេះរដ្ឋយកទៅណា គឺនៅមានក្នុងចិត្តរបស់ពួកគេជាបន្តបន្ទាប់"។

មន្ត្រីនៃក្រុមហ៊ុនឯកជនកូរ៉េមួយរូបដែលសុំមិនបញ្ចេញអត្តសញ្ញាណបានឲ្យដឹងថា ជាទូទៅសម្រាប់ខ្លួនគាត់នៅក្នុងមួយខែ គឺត្រូវជាប់កាតព្វកិច្ចពន្ធប្រាក់ខែនេះ១០ភាគរយ ពោលគឺប្រមាណជា១០០ដុល្លារ ហើយបើសរុបទៅចាប់តាំងពីលោកបានចេញធ្វើការនៅក្នុងរយៈពេលជាង១០ឆ្នាំមកនេះគឺចូលម៉ឺនដុល្លារ ប៉ុន្តែដល់ពេលនេះលុយមិនដឹងទៅឯណា។

លោកបានដាក់ជាសំណួររបៀបលេងសើចផង និងសង្កត់បញ្ហាដោយចម្ងល់ផង ទាក់ទងនឹងរឿងពន្ធប្រាក់ខែនេះ ឥឡូវនេះលោកមានវ័យ៣២ឆ្នាំគឺអាចបង់ពន្ធជូនរដ្ឋប្រមាណជា១០០០ដុល្លារនៅក្នុងមួយឆ្នាំ ចុះបើខ្ញុំអាចធ្វើការដល់អាយុ៦០ឆ្នាំ តើខ្ញុំត្រូវបង់ពន្ធប៉ុន្មាន? ហើយលុយនោះយកទៅណា តើវាយុត្តិធម៌ទេដែលកាត់លុយគេមួយឆ្នាំ១០០០ដុល្លារ ហើយម្ចាស់លុយអត់ទទួលបានអត្ថប្រយោជន៍អ្វីសោះពីការបង់ពន្ធទាំងនោះ។

លោកបានបន្តទៀតថា ដូចនៅស្រុកគេ ពេលដែលគេបានបង់ពន្ធប្រាក់ខែ ឬប្រាក់ផ្សេងៗ គឺរដ្ឋគេមានកាតព្វកិច្ចទំនុកបម្រុងវិញ នៅពេលដែលម្ចាស់ពន្ធមានបញ្ហាសុខភាព ឬពេលចូលនិវត្តន៍មានការគាំពារមួយច្បាស់លាស់ ទោះជាអ្នកនោះធ្វើការនៅក្រុមហ៊ុនឯនជន ឬរដ្ឋក៏ដោយ គឺសុទ្ធតែមានប្រាក់ចូលនិវត្តន៍ ប៉ុន្តែនៅកម្ពុជាគឺសូន្យ។

លោកបានបញ្ជាក់ថា "រដ្ឋគួរតែរិះគិតចំណុចនេះ ដើម្បីឲ្យយុត្តិធម៌សម្រាប់អ្នកដែលជាប់កាតព្វកិច្ចនៃការបង់ពន្ធផង ពីព្រោះថា បើគេយកប្រាក់ទាំងនេះទៅសន្សំនៅធនាគារ យ៉ាងហោចណាស់ក៏គេអាចទទួលអត្ថប្រយោជន៍ជាការប្រាក់ពី២ភាគរយទៅ៧ភាគរយដែរនៅក្នុងមួយឆ្នាំ"។

លោកស្រី សុធារី ជាមន្ត្រីគណនេយ្យករនៃក្រុមហ៊ុនមួយ បានអះអាងពីកន្លែងដូរលុយមួយកន្លែងថា នៅកន្លែងធ្វើការលោកស្រីដែលមានគ្នា១៥នាក់ គឺត្រូវជាប់កាតព្វកិច្ចបង់ពន្ធប្រាក់ខែទាំងអស់គ្នាលើកលែងតែអ្នកអនាម័យម្នាក់ប៉ុណ្ណោះ ដោយសារតែមិនទាល់ដល់កម្រិតដែលត្រូវបង់ពន្ធ។




អគារអគ្គនាយកដ្ឋានពន្ធដារស្ថិតនៅក្នុងខណ្ឌទួលគោក។ រូបថតដោយ ថុង យ៉ត

## "មិនឲ្យពួកគេនិយាយយ៉ាងម៉េច បើអ្នកខ្លះជាប់ពន្ធដល់ទៅ១០០ឬជាង១០០ដុល្លារដែរនោះ នៅក្នុងមួយខែៗ"

លោកស្រីបានបញ្ជាក់ថា "គ្រាន់តែកន្លែងធ្វើការខ្ញុំ នៅក្នុងមួយខែៗខ្ញុំមានកាតព្វកិច្ចរៀបចំបង់ពន្ធជូនរដ្ឋ ប្រមាណជា ៤ លានរៀល ដោយខ្លះជាប់ពន្ធពី ៥ ទៅដល់១៥ភាគរយឯណោះ "។

លោកស្រីបានបញ្ជាក់ថា "លើកលែងតែបុគ្គលិកផ្នែកអនាម័យទេដែលមិនជាប់ពន្ធ ក្រៅពីនោះគឺជាប់ទាំងអស់រាប់ទាំងអ្នកបើកបរ"។

លោកស្រីបានបន្តទៀតថា ពួកគេបានដឹងថាការកាត់ពន្ធប្រាក់ខែនេះ លោកស្រីយកទៅបង់ជូនរដ្ឋ ប៉ុន្តែពួកគេនៅតែលេងសើចនឹងលោកស្រីរាល់តែខែ ឲ្យតែដល់ពេលបើកប្រាក់ខែ។

លោកស្រីបានបញ្ជាក់ថា "មិនឲ្យពួកគេនិយាយយ៉ាងម៉េច បើអ្នកខ្លះជាប់ពន្ធដល់ទៅ១០០ឬជាង១០០ដុល្លារដែរនោះនៅក្នុងមួយខែៗ"។

លោកស្រីបានបន្តថា មិនឲ្យពួកគេឆ្ងល់យ៉ាងម៉េច បើកាត់លុយពួកគេរាល់តែខែហើយមិនដែលប្រាប់ពួកគេថា យកលុយពន្ធនោះទៅធ្វើអ្វីផងនោះ ដូច្នេះរដ្ឋគួរតែពន្យល់ចំណុចទាំងនេះ។

លោកស្រីបានបន្តទៀតថា ករណីដូចជា ក្រុមហ៊ុនធានារ៉ាប់រងជីវិតគឺ មួយឆ្នាំគេកាត់យកតែ៣០០ដុល្លារទេ ប៉ុន្តែរាល់ពេលកាត់ទុកនេះ នៅពេលណាមួយមានឧបទ្ទវហេតុអ្វីមួយកើតឡើងគឺ គេចេញធានារ៉ាប់រងដល់រាប់ម៉ឺនដុល្លារ ហើយដល់កាលកំណត់ណាមួយ លុយនោះអាចឲ្យគេទទួលបានដើមមកវិញផងដែរ ប៉ុន្តែរឿងពន្ធប្រាក់ខែមួយខែស្ងាត់ពីរខែស្ងាត់ ហើយបើគិតមកដល់ពេលនេះ ក្រុមហ៊ុនលោកស្រីបានបានបើក៣ឆ្នាំគឺបានស្ងាត់ចំនួនបីឆ្នាំមកហើយ ។

# "តើប្រាក់បង់ពន្ធខ្ញុំទៅណា"



លោកស្រីបានបន្តទៀតថា នៅពេលបើកប្រាក់ខែម្តងៗនរណាក៏រអ៊ូរដែរពីរឿងកាត់ពន្ធបាក់ខែនេះ ប៉ុន្តែចម្លើយដែលខ្ញុំអាចផ្តល់ទៅពួកគេវិញមានតែថា នេះគឺជាច្បាប់ដែលតម្រូវ ហើយខ្ញុំគឺមានតែអនុវត្តតាមច្បាប់ ពីព្រោះបើមិនកាត់ទេគឺរដ្ឋអាចមានការផាកពិន័យផ្សេងៗ។

លោកស្រីបានបន្តថា ដោយសារតែបញ្ហាពន្ធនេះ ក្រុមហ៊ុន ឬអង្គការ ឬស្ថាប័នមួយចំនួន គេធ្វើតារាងប្រាក់ខែពីរ គឺមួយតារាងប្រាក់ខែពិត និងមួយទៀតគឺតារាងប្រាក់ខែសម្រាប់ប្រកាសពន្ធដើម្បីកាត់បន្ថយការចំណាយទៅលើកាតព្វកិច្ចបង់ពន្ធនេះកុំឲ្យខ្ពស់ពេក។

លោកស្រីបានបញ្ជាក់ថា ដោយសារតែវាអត់អត្ថប្រយោជន៍ ដូច្នេះហើយបានជាក្រុមហ៊ុនមួយចំនួនមិនប្រកាសពន្ធប្រាក់ខែពិត ខ្លះប្រាក់ខែ១.០០០ ដុល្លារ ពេលប្រកាសពន្ធ គឺដាក់ត្រឹមតែ៥០០ ដុល្លារ ដូច្នេះចំនួន បង់ពន្ធក៏ធូរទៅតាមហ្នឹងដែរ ហើយខ្លះប្រាក់ខែ៥០០ដុល្លា ដល់ពេលប្រកាសដាក់ត្រឹម២៥០ ក៏ធូរទៅតាមនោះដែរ"។

លោកស្រីបានបន្តថា ដូចករណីក្រុមហ៊ុនលោកស្រីដែលប្រកាសពន្ធប្រាក់ខែទាំងអស់នេះ គឺម្នាក់ៗត្រូវជាប់ពន្ធផ្សេងៗគ្នា ដោយខ្លះជាប់ពន្ធ៥ភាគរយ ខ្លះ១០ភាគរយ ខ្លះរហូតដល់ទៅ១៥ភាគរយ ហើយគិតជាទឹកប្រាក់វិញ គឺអ្នកខ្លះត្រូវបង់១៥ដុល្លារ ខ្លះ៥០ ខ្លះជាង១០០ ដុល្លារ តាមកម្រិតប្រាក់ខែរបស់ម្នាក់ៗ ហើយប្រាក់ពន្ធនេះ គឺយកទៅបង់នៅធនាគារជាតិ និងទៅប្រកាសនៅពន្ធដានៅតាមសាខានានា តាមខណ្ឌរបស់អគ្គនាយកដ្ឋានពន្ធដា។

ជុំវិញចំណុចទាំងនេះ មន្ត្រីពន្ធដាមួយរូប ដែលនិយាយនៅក្នុងលក្ខខណ្ឌមិនបញ្ចេញអត្តសញ្ញាណ ដោយខ្លីថាពន្ធទាំងនេះត្រូវបានកាត់ទុក គឺដើម្បីរួមចំណែក ជាមួយនឹងប្រាក់ពន្ធពីផ្នែកផ្សេងសម្រាប់យកមកជានាលើសកម្មភាពអភិវឌ្ឍន៍ផ្សេងៗនៅក្នុងប្រទេស ដោយឡែករឿងការគិតគូររឿងអត្ថប្រយោន៍ដូចដែលអ្នកបង់ពន្ធបានឆ្ងល់នោះ គឺកំពុងតែស្ថិតនៅក្នុងការពិភាក្សាកម្រិតអន្តរក្រសួង។

លោកបានបញ្ជាក់ថា "មិនមែនរដ្ឋមិនគិតគូនោះទេ គឺអ្វីៗធ្វើទៅតាមជំហានៗ តាមផែនការដែលបានកំណត់"៕

*ដោយ អរិយបុត្រ*

## អត្រានៃការបង់ពន្ធលើប្រាក់បៀវត្សរ៍ដែលច្បាប់បានកំណត់

យោងទៅតាមឯកសារដែលប្រកាសដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីកំណត់លើការបង់ពន្ធប្រាក់បៀវត្សរ៍បានឲ្យដឹងថា អត្រាពន្ធលើប្រាក់បៀវត្សរ៍ដែលខ្ពស់បំផុតដែលច្បាប់បានកំណត់គឺ ២០(ម្ភៃ) ភាគរយ ។

ប្រភពដដែលបានអះអាងថា សម្រាប់មន្ត្រីរាជការ បុគ្គលិក កម្មករ នានា នៅកម្ពុជាដែលមានប្រាក់បៀវត្សរ៍ត្រឹម ៨០០.០០០ (ប៉ែតសិបម៉ឺន )រៀលចុះក្រោម គឺមិនជាប់ពន្ធទេ ប៉ុន្តែបើចាប់ពី ៨០០.០០១ (ប៉ែតសិបម៉ឺនមួយ )រៀលទៅដល់ ១.២៥០.០០០ (មួយលានពីរសែនប្រាំម៉ឺន )រៀល គឺជាប់ពន្ធ ៥ (ប្រាំ) ភាគរយនៃប្រាក់បៀវត្សរ៍នោះ ។

ប្រភពដដែលបានបន្តទៀតថា ១.២៥០.០០១(មួយលានពីរសែនប្រាំម៉ឺនមួយ) រៀលឡើងទៅដល់ ៨.៥០០.០០០ (ប្រាំបីលានប្រាំសែន )រៀល គឺត្រូវជាប់ពន្ធ១០ (ដប់) ភាគរយហើយ សម្រាប់អ្នកដែលមានប្រាក់បៀវត្សរ៍ ចាប់ពី ៨.៥០០.០០១ (ប្រាំបីលានប្រាំសែនមួយ )រៀល ដល់១២.៥០០.០០០ (ដប់ពីរលានប្រាំសែន) រៀលឡើងទៅ គឺជាប់១៥(ដប់ប្រាំ )ភាគរយ ដោយឡែកសម្រាប់អ្នកដែលលើសពីនេះ គឺត្រូវបង់ពន្ធរហូតដល់ ២០ (ម្ភៃ) ភាគរយ ។

នេះគឺជាការកែសម្រួលថ្មី ដែលអនុវត្តកាលពីអំឡុងឆ្នាំកន្លងទៅ ខណៈដែលមុននេះ អ្នកដែលជាប់ពន្ធលើប្រាក់ខែ គឺមានចាប់ពី ៥០០.០០០(ប្រាំសែន) រៀលឡើងទៅ ៕

## ពន្ធលើប្រាក់បៀវត្សរ៍គឺជាប្រភពចំណូលចូលជាតិដ៏ចំបង

អគ្គនាយកដ្ឋានពន្ធដាបានឲ្យដឹងថា ពន្ធលើប្រាក់បៀវត្សរ៍គឺជាប្រភពចំណូលពន្ធដ៏ចំបងនៅក្នុងចំណោមប្រភពពន្ធនានា ដែលអគ្គនាយកដ្ឋានបានសម្រេចបាននាពេលកន្លងមក ។

យោងទៅតាមសេចក្តីប្រកាសព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដា ដែលបានប្រកាសកាលពីខែមករាកន្លងទៅនេះបានឲ្យដឹងថា កាលពីឆ្នាំ២០១៥កន្លងមកនេះ ចំណូលពន្ធអាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានសរុបមានចំនួន ៥.១៩៦.៧៩៥,៧៦ លានរៀល ប្រមាណជា ១.២៩៩,២០ លានដុល្លារ ដោយពន្ធទាំងនេះបានមកពី ពន្ធលើប្រាក់ចំណេញ ពន្ធប្រាក់បៀវត្សរ៍ ពន្ធអាការលើតម្លៃបន្ថែម ពន្ធអាករពិសេស និង ពន្ធតាមសកម្មភាពអាជីវកម្មផ្សេងៗ ។

ប្រភពដដែលមិនបានបញ្ជាក់ថា ពន្ធបានមកពីប្រាក់បៀវត្សរ៍មានចំនួនប៉ុន្មាននៃពន្ធដែលគេបានប្រមូលមកនោះទេ ប៉ុន្តែគេដឹងថា ជាប្រភពចំបង់មួយ ហើយពន្ធលើប្រាក់បៀវត្សរ៍នេះ គឺមានសេចក្តីរាយការណ៍ថា កើនឡើងប្រមាណជា ១៨,៦ ភាគរយ។ ហើយដោយឡែកនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៦នេះ ពន្ធលើប្រាក់បៀវត្សគឺមានការកើនឡើងរហូតដល់ទៅ ១៥ ភាគរយថែមទៀត៕

# ពិធីប្រសិទ្ធិពរលើប្រេងនិងរំលឹកពាក្យសច្ចាលោកបូជាចារ្យ



លោកអភិបាលនិងបូជាចារ្យដើរឆ្លងកាត់ទ្វារដ៏សុទ្ធដែលស្ថិតនៅក្នុងមណ្ឌលសកម្មភាពភ្នំពេញថ្មី។

លោកអភិបាល និងលោកបូជាចារ្យ ព្រះសហគមន៍កាតូលិកទាំងបីភូមិភាគ បានជួបជុំគ្នា ដើម្បីធ្វើពិធីប្រសិទ្ធិពរលើប្រេង និងរំលឹកពាក្យសច្ចាឡើងវិញរបស់លោកបូជាចារ្យ ដែលមានគ្រីស្តបរិស័ទចូលរួមប្រមាណជិត១០០០នាក់ កាលពីថ្ងៃទី១៦ មីនា កន្លងទៅនៅមណ្ឌលសកម្មភាពភ្នំពេញថ្មី ក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ពិធីប្រសិទ្ធិពរលើប្រេងត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំ គឺធ្វើឡើងមុនពេលបុណ្យព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿងមួយសប្តាហ៍។ លោកឧបដ្ឋាក សែ សាធ បានប្រកាសក្នុងពិធីអំពីអត្ថន័យនៃប្រេងដែលទាំងបីប្រភេទដែលហែយកមកប្រសិទ្ធិពរ និងទុកជានិម្មិត្តរូបនៃព្រះវិញ្ញាណដែលជាព្រះអំណោយទាន ជាពិសេសរបស់ព្រះជាម្ចាស់ ដែលបានជ្រួតជ្រាបនូវគំនិត ព្រមទាំងប្រទាននូវកម្លាំង និងអំណរសប្បាយដល់អស់អ្នកដែលជឿ។ ប្រេងដែលធ្វើពិធីប្រសិទ្ធិពរ គឺរួមមានប្រេងសម្រាប់លាបអ្នកជម្ងឺ ប្រេងសម្រាប់អ្នករៀប ចំខ្លួន ទទួល អគ្គ សញ្ញា ជ្រមុជទឹក និងប្រេងគ្រីស្មាប្រើសម្រាប់អគ្គសញ្ញាជ្រមុជទឹកនិងលាបថ្ងាស អគ្គសញ្ញាតែង តាំង ជា បូ ជា ចារ្យ និង ជា អភិបាល និងសម្រាប់ទីសក្ការៈនានា។

លោកអភិបាលអូលីវីយេ ឆ្មឹតអឺស្លែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបានផ្លុំលើប្រេង និងអធិដ្ឋានដោយនឹកដល់អគ្គសញ្ញានានា និងនឹកដល់ព្រះយេស៊ូដែលបំពេញបេសកកម្មសង្គ្រោះមនុស្សលោក។ លោកអភិបាល និងលោកបូជាចារ្យទាំងអស់ទ្រាបដៃលើប្រេង ទូលអង្វរព្រះជាម្ចាស់ ដើម្បីឲ្យប្រេងដែលលាយជាមួយគ្រឿងក្រអូបទាំងនេះក្លាយជាប្រេងដ៏វិសុទ្ធ ដើម្បីប្រើជាប្រយោជន៍ដល់គ្រីស្តបរិស័ទក្នុងការបង្ហាញពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។

លោកអភិបាលអេនរីគេ ហ្វីការេដូ ជាអភិហាល ព្ុរះសហគមន៍ភូមិភាគបាត់ដំបងបានមានប្រសាសន៍ថា "ប្រេងគឺជានិមិត្តរូបមួយ ដើម្បីឲ្យយើងទទួលឫទ្ធានុភាពនៃព្រះវិញ្ញាណព្រះជាម្ចាស់ ហើយប្រេងនេះ គឺមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាជារបៀបដែលឲ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងចូលមកក្នុងដួងចិត្តរបស់យើង និងដើម្បីឲ្យយើងមានកម្លាំងក្នុងព្រះវិញ្ញាណរបស់ព្រះជាម្ចាស់តាមរយៈប្រេងនេះ"។

លោកអន់តូនីសាមី ស៊ូសៃរាជ្យ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមមានប្រសាសន៍ថា គ្រីស្តបរិស័ទត្រូវតែយល់ឲ្យច្បាស់អំពីអត្ថន័យរបស់ប្រេងទាំងបីប្រភេទនេះ និងចេះប្រើយ៉ាងតិចពីរ គឺផ្តល់កម្លាំងអោយអ្នកជំងឺ និងមួយទៀតផ្តល់សេចក្តីក្លាហាន។

ក្នុងឱកាសនោះដែរ ជាពេលវេលាដែលលោកបូជាចារ្យកាតូលិកទាំងអស់រំលឹកអំពីពាក្យសច្ចាប្រណិធានឡើងវិញ ដែលមាន កាន់ព្រហ្មចារីធម៌ រស់នៅដោយដាក់ខ្លួនជាអ្នកក្រីក្រ និងស្តាប់បង្គាប់។

លោកអភិបាលអូលីវីយេ មានប្រសាសន៍សង្កត់ធ្ងន់ចំពោះលោកបូជាចារ្យទាំងអស់ដែលមានតួនាទីបម្រើនៅព្រះសហគមន៍នានាក្នុងប្រទេសកម្ពុជាថា សូមលោកបូជាចារ្យទាំងអស់នឹកឃើញឡើងវិញនូវពាក្យសច្ចារបស់ខ្លួនក្នុងនាមជាអ្នកបម្រើព្រះសហគមន៍ព្រោះយើងទាំងអស់គ្នាគឺជាឧបករណ៍យ៉ាងសំខាន់របស់ព្រះជាម្ចាស់ដើម្បីប្រកាសដំណឹងល្អ។ លោកអភិបាលបន្តទៀតថា "សូមលោកបូជាចារ្យទាំងអស់សម្លឹងមើលទៅព្រះយេស៊ូ មើលគំរូរបស់ព្រះយេស៊ូ ហើយត្រូវគិតថា ត្រូវធ្វើយ៉ាងណាដើម្បីជួយអ្នកដែលកំពុងតែជួបនូវការលំបាកព្រោះនេះជាឆ្នាំយ៉ាងពិសេស គឺឆ្នាំព្រះមហាករុណាទិគុណសម្តែងព្រះហឫទ័យប្រណីសន្តោស ហើយសូមយើងទាំងអស់គ្នាត្រូវចាំថា "ចូរមានចិត្តមេត្តាករុណាដូចព្រះបិតាដែលមានចិត្តមេតាករុណាដែរ"។

លោកបូជាចារ្យបម្រើការងារនៅក្នុងប្រទេសកម្ពុជាទាំងអស់មានចំនួនសរុបប្រមាណជាង៧០នាក់ ដែលរួមមានទាំងសាសនទូត បព្វជិត និងបូជាចារ្យភូមិភាគ។ ពិធីរំលឹកពាក្យសច្ចាសារជាថ្មីរបស់លោកបូជាចារ្យ និងពិធីប្រសិទ្ធិពរលើប្រេងនេះ ត្រូវបានធ្វើឡើងរួមគ្នា និងធ្វើជារៀងរាល់ឆ្នាំ។

*ដោយដាលីសនិងស្រីម៉ាច*





# សិប្បកម្មតម្បាញផ្តល់ការងារដល់ជនពិការ និងប្រជាជនក្នុងតំបន់



*កម្មករ-ការិនីកំពុងតភ្ជាប់កំណាត់អាវដែលបានត្បាញរួច។ រូបថត កញ្ញា*

*នៅក្រុងបាត់ដំបង ព្រះសហគមន៍កាតូលិក បានបង្កើតសិប្បកម្មតម្បាញមួយដែលអាចជួយសម្រួលដល់ជីវភាពប្រជាជន ក្នុងតំបន់ប្រមាណ ១០០ នាក់។ សិប្បកម្មមួយនេះ បានផ្តល់នូវបរិយាកាសទំនាក់ទំនាក់ទំនង និង អំណរសប្បាយ ដល់អ្នកធ្វើការងារនៅទីនោះ។*

ភ្នែកកំពុងសំលឹងមើល ម៉ាស៊ីនដែលកំពុងតែរវៃមិនឈប់ ជាមួយនឹងអំបោះសរសៃតូចឆ្មារៗ ប្រទាក់គ្នាឥតដាច់ពីមួយទៅមួយ ដែលបានធ្វើឲ្យចេញជាកំណាត់អាវមួយផ្ទាំងពណ៌ប្រផេះ លេចជារូបរាង ដោយមនុស្សមួយក្រុមតូចរវាសរវៃគ្មានសំចៃកំលាំង ខ្លះឈរ ខ្លះក៏អង្គុយ ស្របពេលដែលម៉ាស៊ីនធ្វើចលនាយ៉ាងទ្រហឹងអឺងកង។

អង្គុយលើកៅអី ព្រោះជើងពិការមិនអាចឈរបានយូរ យុវជនលក វីតា ធ្វើការបញ្ជា ម៉ាស៊ីនបណ្តីនិយាយបណ្តើថា "ក្នុងមួយខែអាចធ្វើបានប្រមាណ ៩០ ទៅ១០០ តាមលទ្ធភាពដែលយើងអាចធ្វើបាន។ អត់មានប្រាក់ខែគោលទេ ធ្វើបាន(ចំនួន) ប៉ុន្មានយើងបាន(ប្រាក់)ប៉ុណ្ណឹង"។

វីតា និង យុវជន-នារីជាច្រើនទៀតបានមកធ្វើការនៅក្នុងរោងតម្បាញខោអាវមួយ របស់ព្រះសហគមន៍កាតូលិក ដែលបានរៀបចំឡើង នៅឯខេត្តបាត់ដំបង ដោយមានការគាំទ្រពីលោក គីគេ ហ្វីការេដូ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបងសហការជាមួយនឹង សហគ្រាសតម្បាញមួយនៅទីក្រុងភ្នំពេញ។ សិប្បកម្មតម្បាញនេះបានបង្កើតឡើងកាលពីឆ្នាំ២០១៣។

វីតា បន្ថែមថា ធ្វើការពេលដំបូង គឺមានអ្នកបង្ហាត់កាន់ម៉ាស៊ីនពីបីទៅបួនខែ ព្រោះម៉ាស៊ីននៅទីនេះ គេប្រើជាប្រូក្រាម(program)។ ចំពោះការងារនៅទីនេះ វីតាឲ្យដឹងថា ធ្វើការនៅនេះស្រួលទេ គឺធ្វើការពីម៉ោង៧ព្រឹក ដល់ម៉ោង៥រសៀល។ មានពេលឈប់សំរាកបាយថ្ងៃត្រង់១ម៉ោងកន្លះ។

កំពុងឈរពិនិត្យមើល អំបោះដែលប្រទាក់ខុសក្រឡាគ្នា ដៃម្ខាងកាន់ជន្ទៀសមួយ ដើម្បីទាញក្បាលម្ជុលឲ្យត្រូវតាមផ្នែករបស់វាវិញ យុវនារី ជា សុជាតិ បានស្រដីថា នាងមកធ្វើការនៅទីនេះ បាន១ខែហើយ គឺស្ថិតនៅក្នុងពេលសាកល្បងការងារ។ សុជាតិ "ចូលដំបូងខ្ញុំគិតថាពិបាក តែដល់ពេលរៀនមួយៗទៅងាយស្រួលវិញ។ គេទុកពេលឲ្យយើងរៀនបីខែ បើបីខែនេះរៀនអត់បានយើងត្រូវព្យាយាម គេអត់ដេញយើងចេញទេ"។

នៅក្នុងពេល សាកល្បងការងារនេះ យុវនារីរូបនេះ ទទួលបានប្រាក់ខែ២៤ម៉ឺនរៀល ហើយក្នុងមួយថ្ងៃប្រសិនបើសុជាតិត្បាញអត់សូវខូច នាងទទួលបានអាវ១២ផ្ទាំង ប៉ុន្តែបើខូចច្រើនវិញ ជួនកាលបានតែ៥ ទៅ៨ផ្ទាំងទេ។

នៅក្នុងរោងតម្បាញ របស់ព្រះសហគមន៍កាតូលិក មានកម្មករស្រីប្រុសចំនួន ១០០ នាក់ ដែលកម្មករពាក់កណ្តាល ជាជនពិការ កាយសម្បទា ក្នុងនោះមានស្ត្រីចំនួន៦០នាក់ ដែលធ្វើការក្នុងផ្នែក៣ផ្សេងៗពីគ្នា គឺមានតម្បាញ តភ្ជាប់ និងត្រួតពិនិត្យ។

បើយើងដើរពិនិត្យជុំវិញអគារតម្បាញ គឺមានហ៊ុមព័ទ្ធដោយសួនផ្កាយ៉ាងស្រស់ស្អាត និងមានបំពាក់ប្រព័ន្ធទឹក និងកង្ហារដែលអាចមានខ្យល់ចេញចូលបានយ៉ាងស្រួល។ គ្រាន់តែដើរដល់មាត់ទ្វារចូលរោងតម្បាញ យើងអាចលឺសម្លេងខ្យល់បក់វូៗ និយាយគ្នាសឹងស្តាប់គ្នាមិនសូវបានឡើយ ដោយលាយឡំនឹងសម្លេងម៉ាស៊ីនយ៉ាងទ្រហឹងផង។

លោក ហេមេ សូរ៉ូអា (Jaime Soroa) ជាអ្នកស្ម័គ្រចិត្ត មើលការខុសត្រូវកម្មវិធីរោងតម្បាញនេះ បានឲ្យដឹងថា នៅក្នុងរោងតម្បាញ គឺយើងបានបំពាក់ឧបករណ៍ដើម្បីជួយសម្រួលដល់ការងាររបស់កម្មករ។ យើងមានកង្ហារខ្យល់ធំៗ និងមានប្រព័ន្ធផ្តល់ សំណើមផង ដែលជួយបន្ថយកម្តៅ នៅខាងក្នុងបាន។

លោកហេមេ បន្តថា "យើងគិតអំពីសុខភាព និងសុខមាលភាពរបស់កម្មកររបស់យើង។ យើងក៏មានបំពាក់ប្រព័ន្ធទឹកស្អាត សម្រាប់ញ៉ាំផងដែរ។ នៅពេលដែលកម្មករឈឺ គឺយើងមានសេវាសុខភាពសម្រាប់ពួកគេ ដោយសហការជាមួយមណ្ឌលសុខភាព របស់ព្រះសហគមន៍កាតូលិករបស់យើង"។

លោកបានបន្ថែមថា កម្មវិធីសិប្បកម្មតម្បាញនេះ គឺធ្វើឡើងដើម្បីជួយផ្តល់ការងារដល់ប្រជាជន អាចមានសេដ្ឋកិច្ចគ្រួសារ ទទួលបានចំណូលសមរម្យមួយផ្នែក និងមានជំនាញមួយពិតប្រាកដ ហើយព្រះសហគមន៍ក៏នឹងអាចទទួលបានចំណូលមួយផ្នែក ដើម្បីផ្គត់ផ្គង់កម្មវិធីផ្សេងៗរបស់ព្រះសហគមន៍ផងដែរ។

លោកហេមេ បន្ថែមទៀតក្នុងដើមឆ្នាំ២០១៦នេះ សិប្បកម្មនេះរកបានប្រាក់ចំណេញខ្លះៗហើយបន្ទាប់ពីត្រូវចំណាយជាច្រើនក្នុងអំឡុងឆ្នាំកន្លងទៅ។

លោកបន្ថែមទៀតថា ដោយសារយើងធ្វើដោយមានគុណភាពល្អ អ្នកបញ្ជាទិញគេពេញចិត្ត ហើយបុគ្គលិករបស់យើងក៏កាន់តែស្ទាត់ជំនាញផងដែរ ជាហេតុធ្វើឲ្យការផលិតរបស់យើងក៏កាន់តែប្រសើរឡើងមួយកម្រិត។

កល្យប្រឹក្ស

# គ្រីស្តបរិស័ទជាទ្វារនៃធម៌មេត្តាករុណារបស់ព្រះគ្រីស្ត



*គ្រីស្តបរិស័ទភូមិភាគកំពង់ចាមចូលរួមកម្មវិធីបើកទ្វារដ៏វិសុទ្ធនៅព្រះសហគមន៍ក្តុលលើ។ ដោយកញ្ញា*

ព្រះសហគមន៍កោះរការ បានរៀបចំទ្វារដ៏វិសុទ្ធសម្រាប់ឆ្នាំនៃព្រះមហាករុណាទិគុណ ប្រណីសន្តោសដើម្បីទទួលគ្រីស្តបរិស័ទដែលមានបំណងចង់ធ្វើបូជនីយកិច្ច ដែលធ្វើឡើងកាលពីយប់ថ្ងៃទី២២ ខែកុម្ភៈ ដែលមានគ្រីស្តបរិស័ទមកពីភូមិភាគកំពង់ចាមប្រមាណ២០០នាក់។

មុនពេលដែលធ្វើដំណើរចូលទ្វារដ៏វិសុទ្ធដែលនៅម្ខាងទៀតនៃទ្វាររបស់ព្រះវិហារសន្តហ្វង់ស្វ័រនិងសន្តីក្លារ៉ាអាស៊ីស៊ីនៃព្រះសហគមន៍កោះរការ គ្រីស្តបរិស័ទបានឈរនៅជុំវិញភ្នក់ភ្លើង អធិដ្ឋាននិងនឹករលឹកដល់លោកអន់ ជ្រេឡឺស្វេប ជាអតីតអភិបាល ព្រះសហគមន៍ភូមិភាគកំពង់ចាមពីដើម។ បន្ទាប់មកគ្រីស្តបរិស័ទបានដើរជុំវិញព្រះវិហារចំនួន៣ជុំទើបឆ្ពោះទៅកាន់ទ្វារដ៏វិសុទ្ធ។

ក្នុងពេលធម្មទេសនាលោកអភិបាលអន់តូនីសាមី ស៊ូសែរាជ្យជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមបានមានប្រសាសន៍ថា ព្រះយេស៊ូគឺជាទ្វារ និងជាគង្វាលរបស់យើងជាគ្រីស្តបរិស័ទ។ លោកអភិបាលបានបន្តថា ទ្រព្យសម្បត្តិដ៏មហាសាលរបស់ព្រះសហគមន៍កំពង់ចាម គឺយើងទាំងអស់គ្នាដែលប្រៀបដូចជាផ្ទះ និងជាទ្វារ ដែលជាតំណាងឲ្យព្រះយេស៊ូគ្រីស្ត។ លោកអភិបាលបន្ថែមថា យើងត្រូវទទួលស្វាគមន៍មនុស្សទាំងអស់យើងក៏ទៅរកមនុស្សទាំងអស់ដែលត្រូវការយើងផងដែរ ដោយមិនរង់ចាំតែគេមករកយើងឡើយ។

លោកអភិបាលបាន លើកយកឧទាហរណ៍ដ៏សាមញ្ញ និងជាគំរូសម្រាប់គ្រីស្តបរិស័ទអំពីអតីតលោកអភិបាលអន់ ជ្រេឡឺស្វេប ដែលលោកបានដើរស្វែងរកគ្រីស្តបរិស័ទនៅក្រោយពេលសង្គ្រាមប៉ុល ពតបានបញ្ចប់។ លោកអភិបាលអន់តូនីសាមីបន្តទៀតថា តាមរយៈគំរូនៃបូជាចារ្យ គ្រីស្តបរិស័ទពីដើមនេះ នាំឲ្យមនុស្សជាច្រើនទទួលក្តីសង្ឃឹម និងស្គាល់ព្រះជាម្ចាស់។

លោកអភិបាលបានសង្កត់ធ្ងន់ថា បងប្អូនភាគច្រើនដែលទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងព្រះសហគមន៍ ពីព្រោះពួកគេបានឃើញគំរូដ៏ល្អរបស់គ្រីស្តបរិស័ទ ដែលបានផ្តល់ក្តីសង្ឃឹម លើកទឹកចិត្ត និងជួយទុក្ខធុរៈរបស់អ្នកដទៃដោយមានចិត្តមេត្តាដល់អ្នកដទៃ ដែលណែនាំឲ្យគ្រីស្តបរិស័ទនោះទៅជាទ្វារ។ ក្រោយពួកគេទទួលជ្រមុជទឹកហើយ នាំឲ្យគេហ៊ានបង្ហាញមេត្តាករុណាដល់អ្នកដទៃដែរ។

លោកអភិបាលបានជំរុញឲ្យគ្រីស្តបរិស័ទទាំងអស់មានជំនឿដោយចេះប្រតិបត្តិតាមជំនឿរបស់ខ្លួន ជាគ្រីស្តបរិស័ទ។ លោកអភិបាលអន់តូនីសាមី "យើងដឹងថាជំនឿយើងជាគ្រីស្តបរិស័ទមិនមែនគ្រាន់តែជាទ្រឹស្តីមួយក្នុងខួរក្បាលយើងប៉ុណ្ណោះទេ (តែ)សំខាន់ជាងគឺយើងបង្ហាញសកម្មភាព បង្ហាញចិត្តមេត្តាករុណា(របស់)យើង"។

លោកអភិបាលបានមានប្រសាសន៍អំពីឆ្នាំ មេត្តាករុណានេះថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបើកឲ្យមានឆ្នាំព្រះមហាករុណាទិគុណបង្ហាញព្រះហឫទ័យប្រណីសន្តោសនេះ ដើម្បីឲ្យគ្រីស្តបរិស័ទទទួលស្គាល់ចិត្តមេត្តាករុណា និងការលើកលែងទោសពីព្រះជាម្ចាស់ ដែលនាំឲ្យគ្រីស្តបរិស័ទចេះបង្ហាញចិត្តមេត្តាករុណា ដែលនាំឲ្យអំពើខុសឆ្គងរបស់យើង ការលំបាករបស់យើង បាបរបស់យើងមិននាំឲ្យយើងធ្លាក់ទឹកចិត្តទេ ដោយយើងមានក្តីសង្ឃឹមថា ព្រះជាម្ចាស់ស្រឡាញ់យើង ទទួលយើង។

លោកអភិបាលបន្ថែមថា "ចិត្តមេត្តាករុណា នាំឲ្យអ្នកតូចតាចមានអំណរសប្បាយ នាំឲ្យយើងមានសេចក្តីក្លាហានមិនខ្លាចនរណាទេ។ ដូច្នេះយើងអរព្រះគុណព្រះអង្គដែលអញ្ជើញយើង ឲ្យចូលរួមក្នុងគ្រួសារនៅទីនេះ"។

ព្រះសហគមន៍កោះរការ ស្ថិតនៅភូមិកោះរការក្រៅ ឃុំកោះរការ ស្រុកកំពង់សៀមខេត្តកំពង់ចាម។ព្រះសហគមន៍នេះបានកកើតឡើងក្រោយសម័យសង្គ្រាមដោយពុទ្ធបរិស័ទម្នាក់ព្រមទទួលជឿលើព្រះយេស៊ូគ្រីស្តក្នុងអំឡុងឆ្នាំ១៩៩៥។ ក្រោយមកព្រះសហគមន៍នេះបានរីកចម្រើនឡើងជាលំដាប់ ហើយមានគ្រីស្តបរិស័ទប្រមាណ១៣៣នាក់។

*ដោយកញ្ញា*

## ព្រះសហគមន៍អធិដ្ឋាន២៤ម៉ោង

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានរៀបចំកម្មវិធីអធិដ្ឋានរយៈពេល២៤ម៉ោង តាមការស្នើសុំ និងអញ្ជើញរបស់លោកអភិបាលអូលីវីយេ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ក្នុងសប្តាហ៍ទី៣នៃរដូវអប់រំពិសេសរបស់ព្រះសហគមន៍កាតូលិក ក្រោយពេលដែលសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានចេញសេចក្តីអំពាវនាវឲ្យព្រះសហគមន៍កាតូលិកទូទាំងពិភពលោករៀបចំ។

កម្មវិធីអធិដ្ឋាននេះ បានធ្វើឡើងនៅថ្ងៃសៅរ៍ល្ងាច ដល់ថ្ងៃអាទិត្យព្រឹកដែលត្រូវនឹងថ្ងៃទី ៥និងទី៦ មីនា ដែលការអធិដ្ឋាននេះ ផ្តោតសំខាន់សម្រាប់ប្រទេសកម្ពុជា និងសម្រាប់សន្តិភាពនៅក្នុងពិភពលោកទាំងមូល។

លោកបូជាចារ្យសេន័យឆាល់ វ៉ាំងសង់ ជាបូជាចារ្យទទួលខុសត្រូវនៅមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង មានប្រសាសន៍ថា ព្រះសហគមន៍កាតូលិកបឹងទំពុនក្នុងមណ្ឌលសកម្មភាពនេះ បានរៀបចំឲ្យមានការអធិដ្ឋាន២៤ម៉ោងនេះ គឺចាប់ពីម៉ោង៧យប់ថ្ងៃសៅរ៍ រហូតដល់ព្រឹកថ្ងៃអាទិត្យ។

លោកបូជាចារ្យបន្តថា "យើងបានរៀបចំ គឺមាននិស្សិតនិងយុវជន បងស្រីគណៈកម្មការ និងគ្រីស្តបរិស័ទចូលរួមចុះឈ្មោះចូលអធិដ្ឋាន"។

លោកបានបញ្ជាក់ទៀតថា "កម្មវិធីអធិដ្ឋាននេះ គឺល្អសម្រាប់គ្រីស្តបរិស័ទ ទោះបីជាមានមួយម៉ោង២ទៅបីនាក់ គឺដីម្បីជួយពួកគាត់ក្នុងរដូវអប់រំពិសេសនេះ ជាពេលវេលាដែលយើងត្រូវអធិដ្ឋាន"។

លោកបូជាចារ្យបន្តថា ក្នុងកម្មវិធីនោះ ក៏មានពិធីតាំងព្រះកាយព្រះគ្រីស្តក្នុងព្រះពន្លា ការអធិដ្ឋានសម្រាប់ការត្រាស់ហៅ និងអភិបូជាបញ្ចប់កម្មវិធីនាព្រឹកថ្ងៃទី៦ វេលាម៉ោង៦ព្រឹក។

រដូវអប់រំពិសេសរបស់ព្រះសហគមន៍កាតូលិកជាពលេវលោមួយដលែមានរយៈពេល៤០ថ្ងៃ ដើម្បីឲ្យគ្រីស្តបរិស័ទរិះគិតអំពីជំនឿកាន់តែស៊ីជម្រៅ ដោយមានការតមអាហារ អធិដ្ឋាន ស្តាប់និងរិះគិតព្រះបន្ទូល និងបញ្ចេញសកម្មភាពខាងជំនឿ ដែលត្រូវបម្រើអ្នកក្រីក្រតូចតាច។

*ដោយកែវ កញ្ញា*

# លោកបូជាចារ្យ យ៉ូសែប ឆ្មារ សាឡឹម (១៩៤០-១៩៧៧)

## Father Joseph CHHMAR SALEM

## បូជាចារ្យភូមិភាគភ្នំពេញ



យ៉ូសែប ឆ្មារ សាឡឹម កើតនៅឆ្នាំ ១៩៤៧ នៅភូមិមាត់ក្រសាស់ជាភូមិមួយនៅឆ្ងាយបន្តិចពីទីក្រុងភ្នំពេញ។ ឪពុកម្តាយមានកូនប្រុសស្រី៨នាក់ និងជាអ្នកគោរពប្រណិប័តន៍គ្រីស្ត-សាសនាកាតូលិក។ ក្រុមគ្រួសារនេះបានមករស់នៅទីក្រុងភ្នំពេញក្នុងព្រះសហគមន៍ព្រះមាតា។ នៅក្នុងឆ្នាំ ១៩៧៥ បងប្រុសម្នាក់របស់ សាឡឹម ឈ្មោះ យ៉ូសែប សាឡាស់ បានទទួលតែងតាំងជាលោកអភិបាលឧបត្ថម្ភក នៅព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ។

យ៉ូសែប សាឡឹម បានបំពេញវិជ្ជាកំរិតបឋម និង កំរិតមធ្យមនៅក្នុងប្រទេសកម្ពុជា។ បន្ទាប់មក នៅខែតុលា ឆ្នាំ១៩៦៣ លោកត្រូវបានបញ្ជូនឲ្យទៅបន្តការសិក្សានៅប្រទេសបារាំង ដើម្បីរៀបចំខ្លួនចូលទេវវិទ្យាល័យ Grand Seminaire d' Issy les Moulineaux។ លោកបានទទួលពិធីកាត់សក់ (និស្សិតទេវវិទ្យា-ល័យ = la tonsure) នៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ១៩៦៥ ។ លោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅប្រទេសបារាំង ។

ពេលលោក សាឡឹម វិលត្រឡប់មកប្រទេសកម្ពុជាវិញ លោកបានទទួលមុខងារជាតំណាងពេញសិទ្ធិលោកអភិបាលនៅព្រះវិសាលវិហារភ្នំពេញ។ ក្នុងការណែនាំសហគមន៍គ្រីស្តបរិស័ទខ្មែររហូតដល់ឆ្នាំ១៩៧៥ បេសកកម្មរបស់លោកប្រព្រឹត្តទៅក្នុងបរិយាកាសស្រុកទេសកើតបដិវត្តន៍វឹកវរ និងភ្លើងសង្គ្រាមស៊ីវិលយ៉ាងក្តៅគគុក។ ទីបំផុត នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានសម្រុកវាយប្រហារកាន់កាប់បានទីក្រុងភ្នំ-ពេញ។ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ទីក្រុងភ្នំពេញទាំងមូលធ្លាក់ទៅក្នុងកណ្តាប់ដៃខ្មែរក្រហម ។

ពេលទទួលបានជ័យជំនះ ខ្មែរក្រ-ហមក៏ជន្លៀសប្រជាជនទាំងអស់ដែលរស់នៅក្នុងទីក្រុងទៅកាន់តំបន់នានា និង បង្ខំឲ្យធ្វើការជាទម្ងន់។ លោកយ៉ូសែបសាឡឹមជាមួយលោកអភិបាល សាឡាស់ជាបងប្រុស រួមទាំងឪពុកម្តាយបងប្អូនប្រុសស្រី ព្រមទាំងបូជាចារ្យ២អង្គ ដូនជី៦ នាក់ត្រូវបានជន្លៀសទៅតាមទិសខាងកើត មានចម្ងាយប្រមាណ ១០០ គ.ម ពីទីក្រុងភ្នំពេញ ។ នៅថ្ងៃទី ២ ខែឧសភា ឆ្នាំ ១៩៧៥ ពួកគេបានទៅដល់តាំងគោក។ យ៉ូសែប សាឡឹម ត្រូវធ្វើការងារជាទម្ងន់ជាមួយអ្នកភៀសសឹក ក្រោមការត្រួតពិនិត្យយ៉ាងតឹងរឹងគ្រប់ជំហានទាំងអស់។ ប្រធានភូមិងឿងឆ្ងល់ចំពោះជីវិតលីវរបស់លោកបូជាចារ្យទាំងបី ក៏ប្រើល្បិចកលបង្ខំឲ្យរៀបការ។ ប្រធាននារីភូមិជានារីយោធារំសាយពីកងទ័ព មានបំណងចង់រៀបការជាមួយលោកសាឡឹម ប៉ុន្តែលោកមិនព្រមចុះចាញ់ចំពោះការគំរាមកំហែងមកលើសីល-ធម៌របស់លោកឡើយ ។

ខែកញ្ញា ឆ្នាំ ១៩៧៧ លោកសាឡឹម កើតជម្ងឺហើមស្លឹក ឪពុកនិងបងប្រុសសាឡាស់ ក៏កើតជម្ងឺនេះដូចគ្នាដែរ។ លោកធ្វើការនៅក្នុងកងចល័តលីវ។ ថ្ងៃមួយ គេដាក់លោកនិង លោកសំរើនក្នុងឡានកាម៉ុញ៉ុងមួយនាំយកទៅបន្ទាប់មកគេលែងបានឃើញលោកទាំងពីរជារៀងរហូត។

*អត្ថបទដោយលោករឿង ឆ័ត្រសិរី អ្នករៀបចំសំណុំឯកសារ សម្រាប់មរណសាក្សីនៅប្រទេសកម្ពុជា*




ក្លារ៉ា ជាស្ត្រីម្នាក់ស្ថិតក្នុងត្រកូលស្តុកស្តម្ភ រស់នៅក្នុងក្រុងអាស៊ីស៊ីនៃប្រទេសអ៊ីតាលី។ ម្តាយនាងជាគ្រីស្តបរិស័ទគំរូម្នាក់។ ម្តាយនាងបានអប់រំជំនឿដល់កូន អំពីសេចក្តីស្រ-ឡាញ់របស់ព្រះយេស៊ូចំពោះមនុស្សគ្រប់រូប។ ពេលក្លារ៉ាពេញវ័យ នាងបានជួបនឹងលោក ហ្វ្រង់ស្វ័រអាស៊ីស៊ី ដែលជាបព្វជិត ដែលកាលពីមុនគាត់ជាកូនអ្នកមានទ្រព្យមួយរូប ហើយបានលះបង់នូវអ្វីៗទាំងអស់ដើម្បីដើរតាមព្រះយេស៊ូ។ លោកសុំក្លារ៉ានូវថវិកាខ្លះ ដើម្បីជួសជុលអារាមបាក់បែកឈ្មោះថា អារាមសន្តដាមីញ៉ាណូ។ ថ្ងៃមួយក្លារ៉ាបានសម្រេចចិត្តចាកចេញពីផ្ទះ ដោយមិនឲ្យឪពុកម្តាយដឹងឡើយ ព្រោះនាងដឹងច្បាស់ថាពួកគាត់មិនអនុញ្ញាត។ លោកហ្វ្រង់ស្វ័រ បានកាត់សក់ឲ្យនាងហើយនាំនាងទៅផ្ទះបងស្រី។ ក្រោយមកបងជីដូនមួយម្នាក់ និងអាញែសជាប្អូនរបស់ក្លារ៉ា បានសុខចិត្តរស់នៅតាមគំរូរបស់ក្លារ៉ាដែរ ដែលធ្វើឲ្យឪ-ពុកក្លារ៉ាខឹងយ៉ាងខ្លាំង។ គាត់បានហៅប៉ូលីសឲ្យមកគំរាមកំហែងដល់អារាម។ ពេលនោះក្លារ៉ាបានរត់ទៅអធិដ្ឋានអង្វរព្រះជាម្ចាស់។ មិនយូរប៉ុន្មានមានស្ត្រីៗជាច្រើនចូលបួសដោយរស់នៅក្នុងអារាម ដែលលោកហ្វ្រង់ស្វ័រ ជួសជុលដោយផ្ទាល់ដៃ។ ហេតុនេះលោក ហ្វ្រង់ស្វ័របានជ្រើសរើសក្លារ៉ាជាប្រធាននៅអាយុ ២២ឆ្នាំ ដើម្បីដឹកនាំក្រុមនេះ។ ក្លារ៉ាសុំឲ្យបងស្រីទាំងនោះចាត់ទុកនាងជាអ្នកបម្រើមិនមែនជាប្រធានត្រួតត្រាទេ។

ជីវិតរស់នៅក្នុងអារាមក្រលំបាកណាស់ បងស្រីទាំងអស់ហូបតែនំប៉័ងដែលគេឲ្យ ហើយដេកលើឈើ។ នៅរដូវរងារ ក្លារ៉ាបានចែកភួយរបស់ខ្លួនដល់បងស្រីឯទៀតដណ្តប់។ ជួនកាល ក្លារ៉ាលាងរបួសឲ្យអ្នកជំងឺឃ្លង់ ហើយលើកទឹកចិត្តគេផង។ លោកហ្វ្រង់ស្វ័រ បានក្លាយជាមិត្តជិតស្និទ្ធរបស់ក្លារ៉ា ហើយគាត់បានធ្លាក់ខ្លួនឈឺជាទម្ងន់។ ទោះយ៉ាងណាគាត់នៅតែលើកទឹកចិត្តក្លារ៉ាឲ្យមានជំនឿកាន់តែរឹងមាំ ដាក់ខ្លួនជាអ្នកក្រីក្រ ហើយ បម្រើព្រះជាម្ចាស់ជានិច្ចទៅ។ ក្រោយពេល ហ្វ្រង់ស្វ័រស្លាប់ ប៉ុន្មានឆ្នាំក្រោយមក សម្តេចប៉ាបបានប្រ-កាសលើក ហ្វ្រង់ស្វ័រជាសន្តបុគ្គលនៅក្នុងអារាមដែលក្លារ៉ារស់នៅ។ ឪពុកម្តាយក្លារ៉ាក៏ឈប់ខឹងនឹងកូន និងអត់ទោសឲ្យនាង ព្រោះបានយល់ពីគោលបំណងរបស់កូន។ ក្រោយពេលឪពុកស្លាប់ ម្តាយក្លារ៉ានិងប្អូនពៅ បានសុំចូលអារាមដោយយល់ព្រមស្តាប់បង្គាប់ក្លារ៉ាដែលជាប្រធាន។ ការងារចេះតែចម្រើនទៅមុខ ក្លារ៉ាក៏កាន់តែចាស់ ហើយមានជំងឺទៀត។ ក្លារ៉ាបានទទួលព្រះអំណោយទានពីព្រះជាម្ចាស់ក្នុងការប្រព្រឹត្តការអស្ចារ្យដូចជាពេលនាងដាក់ដៃលើភ្នែកអ្នកខ្វាក់ ពួកគាត់ក៏បានជា។

នៅព្រឹកថ្ងៃទី១១ ខែសីហា ឆ្នាំ ១២៥៣ ក្លារ៉ាបានទទួលមរណភាព។ ពីរឆ្នាំក្រោយមក សម្តេចប៉ាបបានប្រកាសលើកក្លារ៉ាជាសន្តី៕

# លោកអភិបាលជំរុញគ្រីស្តបរិស័ទចេះណែនាំគ្នាទៅវិញទៅមក



*លោកអភិបាល លោកបូជាចារ្យ និងគ្រីស្តបរិស័ទអធិដ្ឋាននៅមុខទ្វារដ៏វិសុទ្ធនៅ កោះរការ។ ដោយកញ្ញា*

ក្នុងពិធីបើកទ្វារដ៏វិសុទ្ធនៃព្រះសហគមន៍ក្តុលលើកាលពីថ្ងៃទី២៣ កុម្ភៈកន្លងទៅ លោកអភិបាលអន់តូនីសាមីស៊ូសៃរាជ្យ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម បានក្រើនរំលឹកដល់គ្រីស្តបរិស័ទ ឲ្យយកចិត្តទុកដាក់ក្នុងការជួយកែតម្រូវគ្នាទៅវិញទៅមក ដោយសម្តែងនូវសេចក្តីមេត្តា និងការអត់ឱនទោសដល់គ្នា ក្នុងឆ្នាំនៃព្រះមហាករុណាទិគុណសម្តែងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់។

លោកអភិបាលបានមានប្រសាសន៍ថា ក្នុងជីវិតរស់នៅរបស់យើងម្នាក់ៗ យើងរស់នៅជាមួយគ្នា ពេលខ្លះអ្នកនៅជាមួយយើង ប្រើពាក្យសម្តីមិនគួរសមស្លៀកពាក់មិនស្អាតយើងប្រកាន់ចំពោះគេ នេះជាលក្ខណៈទូទៅរបស់មនុស្ស។ ទាំងនេះ ធ្វើឲ្យយើងមានរបួសចិត្ត ដោយសារយើងប្រកាន់។ លោកអភិបាលបន្ថែមថា យើងពិបាកស្រឡាញ់អ្នកដទៃដោយសារយើងមានរបួសចិត្ត។ ពេលខ្លះយើងក៏ទទួលស្គាល់ភាពទន់ខ្សោយរបស់ខ្លួនឯងដែរ ហើយយើងក៏ទទួលស្គាល់ភាពខ្សោយរបស់អ្នកដទៃ ដែលនាំឲ្យយើងដឹងខ្លួនថា យើងទន់ទាបដូចសាវ័ករបស់ព្រះយេស៊ូពីដើម ហើយយើងមិនត្រូវមើលងាយមើលថោកអ្នកដទៃឡើយ។ ប្រសិនបើយើងមានភាពទន់ខ្សោយដូចគ្នា ដូច្នេះ គួរឲ្យយើងចេះណែនាំគ្នាទៅវិញទៅមក និងព្យាបាលរបួសចិត្តឲ្យគ្នា។

លោកអភិបាល បានលើកយកគំរូរបស់ព្រះយេស៊ូដែលបានលាងជើងឲ្យសាវ័ករបស់ព្រះអង្គ គឺព្រះអង្គបានបន្ទាបខ្លួន បង្ហាញសេចក្តីស្រឡាញ់ និងបម្រើអ្នកដទៃ និងជាពិសេសគឺព្យាបាលរបួសចិត្តផង។ លោកអភិបាលបន្ថែមថា ការព្យាបាលរបួសចិត្តនេះ គួរឲ្យយើងចាប់អារម្មណ៍ ព្រោះនេះជាកាយវិការនៃចិត្តមេត្តាករុណា។

លោកអភិបាលបានបន្ថែមថា "ឆ្នាំមហាករុណាទិគុណគឺជាទិសដៅមួយដែលរំលឹកយើង ឲ្យយើងទាំងអស់គ្នាមិនគ្រាន់ធ្វើឲ្យអស់ពីសមត្ថភាពបង្ហាញថា យើងពូកែរៀនសូត្រ ឬពូកែរកស៊ី ឬយើងមានកំលាំងពិសេស តែអ្វីដែលពិសេសជាងគេ គឺឲ្យយើងមានមេត្តាករុណា។ ពេលយើងមានចិត្តមេត្តាករុណា យើងមិនត្រូវរិះគន់អ្នកណាទេ គឺយើងត្រូវចេះចាប់អារម្មណ៍ជួយគេ លើកទឹកចិត្តគេ ជួយសម្អាតគេ បើមានអ្វីខុសឆ្គងត្រូវលើកលែងទោសឲ្យគេ"។

ក្នុងនោះដែរ លោកអភិបាលក៏សូមឲ្យគ្រីស្តបរិស័ទទាំងអស់ចេះអរព្រះគុណព្រះជាម្ចាស់។ លោកអភិបាលអន់តូនីសាមី "ដោយសារជីវិតយើងជាមនុស្សឲ្យយើងចេះប្រើកំលាំង ដោយមានចិត្តដូចម្តាយ ដោយមានកិត្តិយសខ្ពស់ ធ្វើអ្វីល្អៗដើម្បីអ្នកដទៃ នោះនាំឲ្យយើងជាសិរីរុងរឿងរបស់ព្រះជាម្ចាស់ យើងមានព្រះជាម្ចាស់គង់សណ្ឋិតជាមួយយើង"។

ក្នុងកម្មវិធីបើកទ្វារដ៏វិសុទ្ធទីបីនៃព្រះសហគមន៍ក្តុលលើក្នុងភូមិភាគកំពង់ចាមនេះ បងប្អូនគ្រីស្តបរិស័ទដែលមកពីព្រះសហគន៍នានាប្រមាណជាង៣០០នាក់ បានចូលរួមក្បួនដង្ហែពីផ្ទះដូនចាស់ យ៉េនមកកាន់ព្រះវិហារ។ ក្នុងវ័យជាង១០០ឆ្នាំ ដូនចាស់រូបនេះមានប្រសាសន៍ផ្តល់សក្ខីភាពអំពីជំនឿ និងរំលឹកនូវរឿងរ៉ាវប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍នៅក្តុលលើក្នុងសម័យសង្រ្គាម ដល់គ្រីស្តបរិស័ទជំនាន់ក្រោយបានដឹង។

លោកយាយយ៉េនសូមឲ្យគ្រីស្តបរិស័ទទាំងអស់ប្រកាន់ភ្ជាប់នូវធម្មវិន័យរបស់ព្រះជាម្ចាស់ យកព្រះជាម្ចាស់ជាទីពឹង និងកុំបោះបង់ជំនឿរបស់ខ្លួន។

ព្រះសហគមន៍ភូមិភាគកំពង់ចាមបានរៀបចំឲ្យមានទ្វារដ៏វិសុទ្ធចំនួនបីកន្លែងដើម្បីឲ្យគ្រីស្តបរិស័ទក្នុងភូមិភាគនេះ អាចចូលរួមធ្វើបូជនីយកិច្ចទទួលសេចក្តីប្រណីសន្តោសពីព្រះជាម្ចាស់។ ទ្វារដ៏វិសុទ្ធទាំងបីនោះមាននៅព្រះសហគមន៍អ្នកលឿង ព្រះសហគមន៍កោះរការ និងព្រះសហគមន៍ក្តុលលើ។

លោកអភិបាលអន់តូនីសាមី ឲ្យដឹងថា ព្រះសហគមន៍និងគ្រីស្តបរិស័ទអាចជ្រើសរើសធ្វើធម្មយាត្រាទៅកាន់ទីតាំងណាមួយក៏បាន ឬក៏អាចធ្វើដំណើរទៅកាន់ទាំងបីកន្លែងក៏បាន ដោយនៅទីកន្លែងនីមួយៗមានបូជាចារ្យទទួលពួកគាត់ ហើយពួកគាត់អាចទទួលអគ្គសញ្ញាលើកលែងទោសពីព្រះជាម្ចាស់បាន៕

ដោយកញ្ញា

# ពិធីទទួលព្រះកាយលើកដំបូងរបស់កុមារនៅបឹងឈ្វូក

លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញអូលីវីយេ ឝ្មីតអីស្លែរ បានប្រារព្ធពិធីអភិបូជា និងជូនព្រះកាយព្រះគ្រីស្ត ដល់កុមារដែលជាកូនគ្រីស្តបរិស័ទចំនួន១៨នាក់ នៅព្រះសហគមន៍បឹងឈ្វូក ស្ថិតនៅក្នុងស្រុកស្អាង ខេត្តកណ្តាលកាលពីថ្ងៃទី១៣ មីនាកន្លងទៅ ដែលមានគ្រីស្តបរិស័ទចូលរួមប្រមាណជាង២០០នាក់។

កុមារីសំ ស្រីពៅ អាយុ១២ឆ្នាំ បាននិយាយថា "រំភើបណាស់ ពេលបានទទួលព្រះកាយព្រះយេស"។ កុមារីរូបនេះ បានបន្ថែម ទោះបីជារូបនាងទទួលពិធីជ្រមុជទឹកពីតូចក្តី ក៏នាងត្រូវរៀនអប់រំជំនឿដើម្បីស្វែងយល់អំពីព្រះជាម្ចាស់។ ស្រីពៅ "ខ្ញុំមកព្រះវិហាររាល់ថ្ងៃ ដើម្បីរៀនអំពីព្រះយេស៊ូ ថ្ងៃអាទិត្យចូលអភិបូជា។ ពេលយប់ប៉ាម៉ាក់នាំអធិដ្ឋាន។ ខ្ញុំរៀនបីឆ្នាំដើម្បីទទួលព្រះកាយ"។

នៅក្នុងពេលថ្លែងអំណរគុណ ដល់អស់អ្នកដែលបានណែនាំជំនឿដល់ខ្លួន ស្រីពៅបាននិយាយថា នាងអរគុណដល់លោកអភិបាល បូជាចារ្យ គ្រូអប់រំជំនឿ ដែលបានអនុញ្ញាតឲ្យនាងនិងមិត្តភ័ក្របានទទួលព្រះកាយ និងអរគុណដល់ឪពុកម្តាយ ដែលបានអប់រំណែនាំជំនឿតាំងពីតូចរហូតមកផងដែរ។ ស្រីពៅបានបន្ថែមថា នាងនឹងយកចិត្តទុកដាក់រក្សាជំនឿ និងរស់នៅតាមជំនឿរហូត ដោយការអធិដ្ឋាននៅជាប់ជាមួយព្រះយេស៊ូ។

កុមារដែលទទួលព្រះកាយព្រះគ្រីស្តលើកដំបូងនេះ មកព្រះសហគមន៍បីកន្លែង គឺស្អាង មាត់ក្រសាស់ និងបឹងឈ្វូក សរុបចំនួន១៨នាក់។

ក្នុងធម្មទេសនា លោកអភិបាលមានប្រសាសន៍ថា សម្រាប់កូនក្មេងដែលបានទទួលព្រះកាយនៅក្នុងពេលនេះ គឺបានទទួលព្រះយេស៊ូផ្ទាល់នៅក្នុងខ្លួន។ លោកអភិបាលបានបន្តថា យើងចូលរួមយ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់នៅក្នុងអភិបូជា និងទទួលព្រះកាយព្រះគ្រីស្ត។

លោកអភិបាលក៏សូមឲ្យឪពុកម្តាយដាស់តឿនកូនៗរបស់គាត់ឲ្យចូលព្រះវិហារជាប្រចាំ និងកូនៗក៏ត្រូវដាស់តឿនឪពុកម្តាយវិញដែរ ពេលពួកគាត់ភ្លេច។

ដោយ កញ្ញា

# សមាជិកចំនួន៦ប្រទេសចែករំលែកបទពិសោធន៍និងរៀនអំពីការប្រែប្រួលអាកាសធាតុ




*រូបថតជុំគ្នារបស់សិក្ខាកាមក្នុងសិក្ខាសាលាស្តីអំពីស្ត្រី និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ដោយផារ៉ា*

ព្រះសហគមន៍កាតូលិកមកពីប្រទេសចំនួន៦បានមកជួបជុំគ្នាដើម្បីសិក្សាស្វែងយល់អំពីការប្រែប្រួលអាកាសធាតុដែលរៀបចំឡើងដោយ ការិយាល័យគ្រហស្ថ និងគ្រួសារ ផ្នែកស្ត្រីនៃសម្ព័ន្ធសភាលោកអភិបាលកាតូលិកនៅអាស៊ី (FABC of OLF & Women's Desk) កាលពីពេលថ្មីនេះ នៅខេត្តបាត់ដំបង។

កញ្ញាវិនឌី លូវីស (Wendy Louis) ជាអគ្គលេខាធិការ សម្រាប់ការិយាល័យគ្រហស្ថ និងគ្រួសារ ផ្នែកស្ត្រីមានប្រសាសន៍ថា "កិច្ចប្រជុំនេះ ផ្តោតសំខាន់លើស្ថានភាពរបស់ស្ត្រីដែលកំពុងប្រឈមមុខនឹងភាពក្រីក្រ និង គ្រោះធម្មជាតិដែលបានកើតឡើងដោយការប្រែប្រួលអាកាសធាតុ"។ អគ្គលេខាធិការិនីរូបនេះ បន្តថា ដូច្នេះ យើងគិតថាវាក៏មានសារៈសំខាន់ដែរដែលនិយាយអំពីឯកសារឡាវដាតូស៊ី (Laudato Si) របស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ដែលលោកតែងតែសង្កត់ធ្ងន់អំពីបញ្ហានេះ។ ហើយយើងក៏ចង់ឲ្យឯកសារនេះភ្ជាប់ទំនាក់ទំនងនឹងតួនាទីស្ត្រី និងដើម្បីជួយអភិវឌ្ឍន៍ដល់ស្ថានភាពរបស់ពួកគាត់ ដែលកើតឡើងដោយសារការប្រែប្រួលអាកាសធាតុ។

ការិយាល័យគ្រហស្ថនិងគ្រួសារ ផ្នែកស្ត្រី ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៨៤ ដែលផ្តោតសំខាន់ទៅលើផលប៉ះពាល់និងការយកចិត្តទុកដាក់ទៅលើស្ត្រី ហើយដើម្បីលើកទឹកចិត្ត និងផ្តល់ឱកាសដល់ស្ត្រីចូលរួមសហការជាមួយនឹងបុរសដើម្បីបំពេញបេសកកម្មរបស់ព្រះសហគមន៍។

អគ្គលេខាធិការិនីរូបនេះ ឲ្យដឹងថា "ខ្ញុំគិតថាវាជារឿងសំខាន់ណាស ដែលយើងមកប្រទេសកម្ពុជា ព្រោះថារាល់កិច្ចប្រជុំរបស់ FABC គឺយើងធ្វើយ៉ាងណាដើម្បីជំរុញឲ្យមានការចូលរួមពីសហគមន៍ក្នុងតំបន់ក្នុងកិច្ចពិភាក្សា។ ដូច្នេះ យើងត្រូវទៅកន្លែងណា ដែលមិនទាន់មានមនុស្សចូលរួមប្រជុំជាមួយយើង។ ហើយខ្ញុំឃើញថា កាលពីមុន ប្រទេសកម្ពុជាហាក់ដូចជានៅឆ្ងាយពីយើងក្នុងចំណោមប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍។ ហេតុនេះ ខ្ញុំបានស្នើសុំឲ្យមានកិច្ចប្រជុំថ្នាក់តំបន់នៅបាត់ដំបងនេះ"។

កញ្ញាវិនឌី បានបន្ថែមថា ក្នុងខេត្តបាត់ដំបង ជាកន្លែងមួយដែលមានអ្វីៗស្រាប់និងអ្វីដែលកំពុងបន្តរងការប៉ះពាល់ដែលយើងចង់បង្ហាញដល់អ្នកចូលរួមឲ្យបានដឹងក្នុងដំណើរទស្សនកិច្ចសិក្សា។

វិនឌី លូវីស បន្តថា អ្វីដែលយើងរំពឹងពីសិក្ខាសាលារយៈពេលប៉ុន្មានថ្ងៃនេះ គឺអ្នកចូលរួមអាចរៀនពីគ្នាទៅវិញទៅមក អំពីវិធីសាស្ត្រនានា គំនិតច្នៃប្រឌិតថ្មី ការមើលឃើញអ្វីដែលថ្មី និងអាចរកការគាំទ្រពីគ្នាទៅវិញទៅមក។ ជាការពិត បណ្តាញទំនាក់ទំនង ការគាំទ្រគ្នា ដោយមានសាមគ្គីភាពក្នុងតំបន់ជារឿងសំខាន់ណាស់ ពីព្រោះក្នុងថ្នាក់តំបន់របស់យើង យើងមានបញ្ហាស្រដៀងគ្នា ទាំងសង្គម ភូមិសាស្ត្រ និងនយោបាយជាដើម។

វិនឌី បាននិយាយទៀតថា កិច្ចប្រជុំសម្រាប់ការិយាល័យគ្រហស្ថនិងគ្រួសារ ផ្នែកស្ត្រីថ្នាក់តំបន់អាស៊ីអាគ្នេយ៍ មិនត្រូវបានលើកឡើងជាទៀងទាត់ទេ គឺអាចមានមួយឆ្នាំកន្លះទៅ២ឆ្នាំម្តង ដើម្បីទុកឱកាសឲ្យសមាជិកអាចបំពេញគម្រោងកម្មវិធីរបស់ខ្លួន រៀនពីអ្នកដទៃ និងស្គាល់គ្នាឲ្យបានច្បាស់ជាងមុន។

លោកអភិបាល គីគេ ហ្វីការេដូ មានប្រសាសន៍ថា "ខ្ញុំមានការសប្បាយចិត្តដោយសារអង្គប្រជុំផ្តោតលើបញ្ហាទាំងពីរ (ការប្រែប្រួលអាកាសធាតុនិងការចូលរួមរបស់ស្ត្រី)ត្រូវនឹងភូមិភាគបាត់ដំបងយើង។ វាមានបញ្ហាច្រើនខាងបរិស្ថានមីននិងការប្រែប្រួលអាកាសធាតុជាពិសេសប៉ះពាល់ដល់នារីដែលនៅតាមភូមិដែលត្រូវទ្រាំច្រើនក្នុងបញ្ហាសេដ្ឋកិច្ចក្រុមគ្រួសារ ដោយសារគាត់នៅក្នុងភូមិត្រូវចិញ្ចឹមកូននិងបញ្ហាដោះស្រាយមិនចេញ (និង)ឲ្យយើងរិះគិត សួរសុខទុក្ខ ហើយសម្រាប់បងប្អូនដែលមកពី ស្រុកក្រៅមករៀនអំពីទីនេះនឹងជួយយើងច្រើន"។

កម្មវិធីសិក្ខាសាលានេះមានរយៈពេលបីថ្ងៃគឺចាប់ពីថ្ងៃទី ៨-១០ មីនា ដែលមានសមាជិកចូលរួមចំនួន៣២នាក់ មកពីប្រទេសម៉ាឡេស៊ី កម្ពុជា ថៃ ឡាវ ហ្វីលីពិន និងឥណ្ឌូនេស៊ី។

នៅក្នុងសិក្ខាសាលានេះ សិក្ខាកាមទាំងអស់ បានរិះគិតអំពីឯកសារមួយដ៏សំខាន់របស់ព្រះសហគមន៍កាតូលិក គឺឡាវដាតូស៊ី ដែលសរសេរដោយសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ។ ឡាវដាតូស៊ីគឺជាឯកសារស្តីអំពី ការសិក្សាអំពីការវិភាគវិទ្យាសាស្ត្រ និង ការសិក្សាអំពីទំនាក់ទំនងធម្មជាតិ និង បរិស្ថានមនុស្ស។ លោកបូជាចារ្យ សែងធាន ពិឈិត ជាវាគ្មិនក្នុងអង្គប្រជុំបានបង្ហាញពីឯកសារនោះ និងរំលើកអំពីចំណុចសំខាន់ដែលមានដូចជា ទំនាក់ទំនងរបស់មនុស្សនិងធម្មជាតិដែលជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់ និងការប្រើប្រាស់ធនធានធម្មជាតិដោយគោរពនិងសន្សំសំចៃជាដើម។

លោកបូជាចារ្យពិឈិតមានប្រសាសន៍ថា យើងពិបាកណាស់ក្នុងការប្រឆាំងអំពីការប្រែប្រួលអាកាសធាតុ ដោយសារតែមានក្រុមហ៊ុនធំៗជាច្រើនបានចូលរួមធ្វើឲ្យកើតមានឡើងទៅហើយ។ ប៉ុន្តែសម្រាប់យើងផ្ទាល់ យើងត្រូវចាប់ផ្តើមពីខ្លួនយើងជាមុនសិន រួចទៅកាន់អ្នកដទៃដោយយល់ដឹង គោរព និងថែរក្សាស្នាព្រះហស្តរបស់ព្រះជាម្ចាស់។

ក្នុងកម្មវិធីនោះ សិក្ខាកាមទាំងអស់បានចុះទស្សនកិច្ចចំនួន៥កន្លែងក្នុងព្រះសហគមន៍តំបន់បាត់ដំបងក្រុង។ តាមការចាប់អារម្មណ៍របស់ក្រុមនីមួយៗបានឲ្យដឹងថា ជីវិតរបស់អ្នកភូមិជាពិសេសស្ត្រីៗ ត្រូវបានប៉ះពាល់ខ្លាំងដោយសារការប្រែប្រួលនៃអាកាសធាតុនៅក្នុងស្រុកដែលមានការខ្វះទឹកស្អាតបរិភោគ ខ្វះទឹកបង្កបង្កើនផល ភាពរាំងស្ងួតពីមួយឆ្នាំទៅមួយឆ្នាំដែលធ្វើឲ្យទិន្នផលធ្លាក់ និងបង្កឲ្យមានចំណាកស្រុកទៅក្រៅប្រទេស។ ក្នុងនោះ ដែរក៏មានផលប៉ះពាល់មួយចំនួនទៀតដូចជា របររកស៊ីផ្លូវភេទ ការជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ បង្កឲ្យមានភាពក្រីក្រ បញ្ហាសង្គ្រាម អំពីពុករលួយ និងការគ្រប់គ្រងគ្មានតម្លាភាពរបស់អ្នកដឹកនាំ។

មុនពេលបញ្ចប់អង្គសិក្ខាសាលានេះ ប្រទេសដែលជាសមាជិកក្នុងតំបន់នីមួយៗបានធ្វើគម្រោងការសម្រាប់តំបន់របស់ខ្លួន ដែលផ្តោតសំខាន់លើការអប់រំអំពីការប្រែប្រួលអាកាសធាតុ គម្រោងបន្សាំទៅនឹងការប្រែប្រួលទាំងនេះនៅព្រះសហគមន៍និងសហគមន៍នានាដែលព្រះសហគមន៍មានសកម្មភាព។

លោកអភិបាលគីគេមានប្រសាសន៍ដែរថា លោកនឹងស្នើសុំឲ្យក្រុមលោកអភិបាលនៅកម្ពុជា បកប្រែឯកសារអំពីឡាវដាតូស៊ី ដើម្បីអប់រំដល់សហគមន៍អំពីការប្រែប្រួលអាកាសធាតុផងដែរ។

កញ្ញា ឈុន អ៊ី មកពីព្រះសហគមន៍កំពង់ចាមបាននិយាយថា បន្ទាប់ពីបញ្ចប់កិច្ចប្រជុំនៅបាត់ដំបងនេះ នាងនឹងយកអ្វីដែលបានរៀនជម្រាបជូនដល់លោកអភិបាលព្រះសហគមន៍កំពង់ចាម អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការទប់ស្កាត់ ដើម្បីជាប្រយោជន៍ដល់សហគមន៍។ ឈុន អ៊ីបន្តថា គាត់នឹងរៀបចំឲ្យមានការអប់រំមួយចំនួននៅក្នុងគម្រោងមួយចំនួនរបស់ភូមិភាគកំពង់ចាមជាមួយយុវជននៅទីនោះផងដែរ៕

ដោយកញ្ញា

# ដុនបូស្កូជាសាលាព្រះសហគមន៍ដែលបង្ហាញវត្តមាននៅកម្ពុជា២៥ឆ្នាំ



ប្រជាពលរដ្ឋ និស្សិត សាស្ត្រាចារ្យ មន្ត្រីរាជការ គ្រីស្តបរិស័ទប្រមាណជាងមួយពាន់នាក់ បានជួបជុំគ្នានៅសាលាបច្ចេកទេសដុនបូស្កូនៅសង្កាត់ភ្នំពេញថ្មី ដើម្បីអបអរសាទរខួប២៥ឆ្នាំនៃវត្តមានដុនបូស្កូនៅប្រទេសកម្ពុជា។

ពិធីនេះ ត្រូវបានរៀបចំឡើងដោយព្រះសហគមន៍កាតូលិកនៅកម្ពុជាក្រោមអធិបតីភាពលោក អូលីវីយេ ឝ្មីតអីស្លែរ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងលោកអាន ហែលហ្វេនានដេស អារទីមី បូជាចារ្យទទួលបន្ទុកប្រធានសាលាដុនបូស្កូទូទាំងពិភពលោក និងភ្ញៀវកិត្តិយសជាច្រើននាក់ទៀត កាលពីថ្ងៃទី២៩ ខែកុម្ភៈ ២០១៦ កន្លងទៅនេះ។

លោកបូជាចារ្យរ៉ូអែល សូតូជាអធិការនៃសាលាដុនបូស្កូ បានស្វាគមន៍និងប្រកាសបើកកម្មវិធី២៥ឆ្នាំដែលសាលាដុនបូស្កូមានវត្តមាននៅកម្ពុជា ព្រមទាំងថ្លែងអំណរគុណដល់លោកអភិបាល អូលីវីយេ។

លោកអភិបាល អូលីវីយេ បានមានប្រសាសន៍ សម្តែងនូវការកោតសរសើរដល់សាលាដុនបូស្កូដែលតែងតែយកចិត្តទុកដាក់ផ្តល់នូវចំណេះដឹងវិជ្ជាជីវៈចំពោះអ្នកតូចតាច ជាពិសេសយុវជនដែលពុំមានលទ្ធភាពបន្តការសិក្សា។

លោកអភិបាលក៏បានឆ្លៀតពេលចូលរួមផ្តល់នូវអនុសាសន៍ចំនួន ៣ចំណុចសំខាន់ៗនារដូវ៤០ថ្ងៃ និងជាពិសេសក្នុងឆ្នាំមហាករុណាទិគុណទៅ កាន់អ្នកចូលរួម គឺជំរុញឲ្យគ្រប់គ្នាមានសេចក្តីស្រឡាញ់ដោយមានចិត្តអាណិតមេត្តា និងដោយយកចិត្តទុកដាក់ជានិច្ច ឲ្យទាំងអស់គ្នាចេះណែនាំនិងផ្តល់យោបល់ដល់គ្នាទៅវិញទៅមកដោយចេះចែកអំណរសប្បាយដល់គ្នា និងចេះទទួលស្វាគមន៍គ្នាជានិច្ចដោយមិនរើសអើងអ្នកមានឬអ្នកក្រ។

លោកអភិបាលក៏បានពន្យល់បន្ថែមដោយផ្តាំផ្ញើថា "លោកឪពុកដុនបូស្កូគាត់បន្តបេសកម្មដើម្បីបង្ហាញថា ព្រះជាម្ចាស់មានព្រះជន្មគង់នៅ និងពោរពេញទៅដោយសេចក្តីស្រឡាញ់ ហើយនេះជារបៀបដែលយើងទាំងអស់គ្នាបន្តផ្ញើតទៅទៀតជាមួយអ្នកដែលលំបាកអស់សង្ឃឹម ដោយដឹង ឃើញ ឮ យល់ចិត្តពីគេ និងចុះទៅអនុវត្តដើម្បីឲ្យគេមានក្តីសង្ឃឹមឡើងវិញ និងដើម្បីបង្កើតសង្គមថ្មីដែលមានភាពយុត្តិធម៌ សេចក្តីសង្ឃឹម និងសុខសន្តិភាព"។

លើសពីនេះទៅទៀតលោកអភិបាលអូលីវីយេ ក៏បានសំណូមពរដល់សាលាដុនបូស្កូឲ្យបន្តគិតគូរបន្ថែមទៀតចំពោះកម្មករ កម្មការិនី ដែលបោះបង់ចោលការសិក្សាដើម្បីធ្វើការ ឲ្យទទួលបានការអប់រំ ប្រឹក្សាផ្លូវចិត្ត និងអនាម័យជាដើម។

សាលាដុនបូស្កូ បានចាប់ផ្តើមបេសកកម្មជាមួយប្រជាជនកម្ពុជាក្នុងឆ្នាំ១៩៨៩នៅជាយដែនកម្ពុជាថៃ និងបានចូលមកកម្ពុជាក្នុងឆ្នាំ១៩៩១ ដែលមានទិសដៅសំខាន់គឺ អប់រំកុមារនិងយុវជនដលែមានពីកម្រិតមត្តេយ្យសិក្សាដល់បច្ចេកទេសនិងវិជ្ជាជីវៈ។ បច្ចុប្បន្នមាននៅភ្នំពេញ បាត់ដំបង ប៉ោយប៉ែត និងក្រុងព្រះសីហនុ៕ *ដោយដាលីស*

# គ្រួសារអ្នកផ្ទុកមេរោគនិងអ្នកជំងឺអេដស៍ ទទួលអំណោយឆ្នាំថ្មី



ដោយសហការជាមួយមន្ទីរធម្មការនិងសាសនាខេត្តតាកែវព្រះសហគមន៍កាតូលិកនៃភូមិចំការទៀងបានរៀបចំពិធីសំណេះសំណាលចែកអំណោយដល់អ្នករស់នៅជាមួយមេរោគអេដស៍ និងអ្នកជំងឺអេដស៍ចំនួនមួយរយគ្រួសារ ក្រោមអធិបតីភាពលោកអូលីវីយេ ឝ្មីតអីស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងមន្ត្រីនៃមន្ទីរធម្មការនិងសាសនាខេត្តតាកែវជាច្រើននាក់។

ពិធីនោះប្រព្រឹត្តទៅនៅថ្ងៃទី២៩ខែមីនាឆ្នាំ២០១៦នៅសាលាប្រជុំនៃមន្ទីរធម្មការនិងសាសនាខេត្តតាកែវ។ ពេលចាប់ផ្តើមកម្មវិធីលោក គាំ ដាំផេង អនុប្រធានមន្ទីរធម្មការនិងសាសនាខេត្ត បានសំដែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានគណៈប្រតិភូទាំងអស់ និងបានរាយការណ៍ជូនអង្គពិធីបានជ្រាបថា ពិធីសំណេះសំណាស់នេះតែងបានរៀបចំជាប្រចាំសម្រាប់បងប្អូន ដោយមានកិច្ចសហការល្អរវាងព្រះសហគមន៍កាតូលិកសន្តីម៉ារីញញឹមភូមិចំការទៀង និងមន្ទីរធម្មការ និងសាសនាខេត្ត ដែលមានលោកអភិបាលអូលីវីយេជាអ្នកគាំទ្រ។ ពេលនេះបងប្អូនដែលត្រូវទទួលអំណោយមួយរយនាក់ ប្រុសចំនួន៣៣នាក់ និងស្ត្រីចំនួន៦៧នាក់។ លោកអនុប្រធានបន្តថា បងប្អូនទាំងនេះសុទ្ធតែជាអ្នកមានជីវភាពក្រីក្របំផុត។

លោកអូលីវីយេ ឝ្មីតអីស្លែរ អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ បាន៍លើកទឹកចិត្តបងប្អូនអ្នករស់នៅជាមួយមេរោគ និងអ្នកជំងឺអេដស៍ ទាំងអស់ដែលមានវត្តមានក្នុងអង្គពិធីថា៖ ត្រូវរក្សាសេចក្តីសង្ឃឹមជានិច្ច យើងរស់នៅដើម្បីឲ្យកូនមានអនាគត។ ត្រូវមានសេចក្តីសង្ឃឹម ព្រោះសព្វថ្ងៃនេះយើងមានថ្នាំសម្រាប់ព្យាបាល និងសង្គមទាំងមូលមិនរើសអើងយើងទេ។ សេចក្តីសង្ឃឹម ជាកម្លាំងកាយ កម្លាំងចិត្តឲ្យយើងបន្តទៅមុខ។ ក្នុងនោះលោកក៏បានផ្តាំផ្ញើឲ្យបងប្អូនថែរក្សាចិត្តមេត្តា។ លោកអភិបាល "មេត្តាករុណាជំរុញឲ្យយើង បង្កើតសាមគ្គីភាពរវាងគ្នានឹងគ្នា។ ធ្វើយ៉ាងណាឲ្យចេះបង្កើតទំនាក់ទំនង ស្រឡាញ់គ្នា គោរពគ្នា និងមានមេត្តាចំពោះគ្នាទៅវិញទៅមក ជាពិសេសមានមេត្តាចំពោះកូនៗ ឲ្យកូនបានរៀនសូត្រ កសាងអនាគតបាន។ ពេលគេមានចំណេះដឹងគេអាចរកការងារធ្វើបាន និងថែរក្សាឪពុកម្តាយវិញ"។ លោកបានលើកទឹកចិត្តថា ម្នាក់ៗជីវិតមានតម្លៃ មានសេចក្តីថ្លៃថ្នូរ ហេតុនេះកុំអស់សង្ឃឹម ត្រូវខិតខំរស់ដើម្បីឲ្យកូនមានអនាគត ហើយខ្លួនឯងមានអនាគតដែរ។

*ដោយ លី សុវណ្ណា*



*លោកបូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងសូដ៍*

**ថ្ងៃទី ៣ មេសា ត្រូវនឹងថ្ងៃអាទិត្យទី ២ នៃបុណ្យចម្លង ៖ កក ៥: ១២-១៦**

អត្ថបទនេះស្តីអំពី ព្រះសហគមន៍ដើមដំបូង។ តាមរបៀបនិពន្ធរបស់លោកលូកាដែលលើកតម្កើងព្រះសហគមន៍ធ្វើជាគំរូ។ គ្រីស្តទូតជាអ្នកដែលព្រះយេស៊ូចាត់ឲ្យទៅ បានពោរពេញដោយឫទ្ធានុភាពរបស់ព្រះគ្រីស្ត ដែលមានព្រះជន្មថ្មីដ៏រុងរឿង អស់លោកបន្តសកម្មភាពរបស់ព្រះអង្គ គឺសម្តែងសញ្ញាសម្គាល់ដ៏អស្ចារ្យជាច្រើន ដូចព្រះយេស៊ូកាលពីដើមដែរ។ យើងជាគ្រីស្តបរិស័ទតាំងពីកំណើតក្តី ថ្មីក្តី តើយើងសម្តែងឲ្យគេដឹងថា យើងរស់នៅតាមរបៀបប្លែកពីគេ គឺមិនគ្រាន់តែស្វែងរកប្រាក់ចាយដូចគេ មិនស្វែងរកកិត្តិយស ឬស្វែងរកអំណាច ដើម្បីជាប្រយោជន៍របស់ខ្លួនទេ តែយើងមានទិសដៅក្នុងដំណើរនៃជីវិត គឺយើងធ្វើដំណើរទៅកាន់ព្រះបិតាទាំងសុខចិត្តខាតពេលវេលា ខាតប្រាក់ចាយសម្រាប់អ្នកដទៃ ព្រោះអ្នកដទៃក៏ជាបុត្រធីតារបស់ព្រះបិតាដូចយើងដែរ។

"គ្មាននរណាហ៊ានមកចូលរួមជាមួយក្រុមគេ" ព្រោះអ្នកស្រុកយល់ឃើញថា ក្រុមគ្រីស្តបរិស័ទ ជាអ្នកដែលរួមរស់ជាមួយព្រះគ្រីស្តបែបគួរឲ្យគេចាប់អារម្មណ៍យ៉ាងខ្លាំង។ យើងមិនផ្សព្វផ្សាយសាសនាទេ តែយើងទាក់ទាញចិត្តគេដោយឲ្យគេឃើញថា របៀបក្រុមយើងរស់នៅដោយមានព្រះវិញ្ញាណ របស់ព្រះគ្រីស្តណែនាំ។

**ថ្ងៃទី ១០ មេសា ត្រូវនឹងថ្ងៃអាទិត្យទី ៣ នៃបុណ្យចម្លង ៖ កក ៥:២៧-៣២.៤០-៤១**

ក្នុងប្រទេសជាច្រើន គេហាមមិនឲ្យគ្រីស្តបរិស័ទប្រកាសជំនឿរបស់ខ្លួន។ នៅប្រទេសកម្ពុជាយើង ប្រជាជនមិនសូវពេញចិត្តឲ្យយើងកាន់តាមព្រះគ្រីស្ត ព្រោះគេថា យើងលះបង់ប្រពៃណីជាតិ។ រឿងនេះមិនមែនថ្មីៗទេ គឺកាលពីដើមក៏ដូច្នោះដែរ។ តែគ្មាននរណាអាចហាមមិនឲ្យប្រកាស ជំនឿរបស់ខ្លួនបានទេ "យើងខ្ញុំត្រូវស្តាប់បង្គាប់ព្រះជាម្ចាស់ជាជាងស្តាប់បង្គាប់មនុស្ស"។ ហេតុនេះ យើងត្រូវមានចិត្តក្លាហានដូចក្រុមគ្រីស្តទូតពីដើម ដែលហ៊ានប្រឆាំងនឹងមហាបូជាចារ្យ ដែលជាមេដឹកនាំប្រជាជនក្នុងនាមព្រះជាម្ចាស់។តើខ្ញុំហ៊ាននិយាយថា ខ្ញុំជាគ្រីស្តបរិស័ទឬយ៉ាងណា? ពេលយើងត្រូវគេធ្វើបាប ព្រោះយើងកាន់គ្រីស្តសាសនាយើងត្រូវមានអំណរដោយខ្លួនរួមរស់រួមស្លាប់ជាមួយព្រះយេស៊ូដែលរងទុក្ខលំបាក។

**ថ្ងៃទី ១៧ មេសា ត្រូវនឹងថ្ងៃអាទិត្យទី ៤ នៃបុណ្យចម្លង ៖ ១៣:១៤.៤៣-៥២**

ព្រះសហគមន៍ញែកលោកប៉ូល និងលោកបារណាបា ឲ្យទៅប្រកាសដំណឹងល្អ។ ក្នុងអត្ថបទនេះ លោកទាំងពីរប្រកាសដំណឹងល្អអំពី ព្រះយេស៊ូជាព្រះគ្រីស្តដល់ជនជាតិយូដា និងដល់អ្នកចូលសាសនាយូដា។ ជនជាតិយូដាតែងតែគោរពព្រះជាម្ចាស់ តែមិនព្រមផ្ញើជីវិតលើលោកយេស៊ូដែលជាព្រះគ្រីស្ត និងជាព្រះអម្ចាស់ ជាស្ពានមេត្រីដែលនាំឲ្យមនុស្សលោកអាច ទទួលព្រះជន្មផ្ទាល់របស់ព្រះជាម្ចាស់ឡើយ។ សព្វថ្ងៃ នៅប្រទេសកម្ពុជាយើង តើខ្ញុំហ៊ានប្រកាសដំណឹងល្អអំពីព្រះយេស៊ូយ៉ាងដូចម្តេច? យើងមិនត្រូវប្រកាសជំនឿរបស់ខ្លួនជាសាធារណៈដូចលោកប៉ូលនៅវិហាររបស់គេទេ តែយើងត្រូវឆ្លៀតគ្រប់ឱកាសឲ្យអ្នកដទៃបានស្គាល់ព្រះគ្រីស្ត។ ប្រសិនបើយើងស្រឡាញ់គេគឺយើងមានបំណងឲ្យគេមានព្រះជន្មរបស់ព្រះជាម្ចាស់ក្នុងខ្លួនដូចយើងដែរ។

**ថ្ងៃទី ២៤ មេសា ត្រូវនឹងថ្ងៃអាទិត្យទី ៥ នៃបុណ្យចម្លង៖ កក ១៤: ២១-២៧**

គ្រីស្តបរិស័ទមិនផ្ញើជីវិតលើព្រះយេស៊ូជាព្រះអម្ចាស់ម្តងជាស្រេចទេ គឺខ្លួនមានមន្ទិលសង្ស័យខ្លះ ព្រោះជំនឿមិនមែនជាចំណេះទេ។ កាលពីដើមក៏ដូចសព្វថ្ងៃដែរ ពេលគ្រីស្តបរិស័ទជួបឧបសគ្គគេចង់លះបង់ជំនឿ។ ហេតុនេះហើយបានជាលោកប៉ូលតែងតែលើកទឹកចិត្តគេថា "យើងត្រូវឆ្លងកាត់ទុក្ខវេទនាជាច្រើនដើម្បីទទួលជីវិតក្រោមអំណាចរបស់ព្រះជាម្ចាស់"។ ពេលកើតទុក្ខសូមកុំអស់សង្ឃឹម គឺទុក្ខវេទនាពិតជាសញ្ញាសម្គាល់បញ្ជាក់ថា ជំនឿរបស់បងប្អូនកំពុងតែចម្រើនឡើង។ "នៅក្នុងព្រះសហគមន៍នីមួយៗ លោកទាំងពីរបានតែងតាំងព្រឹទ្ធាចារ្យ"។ នៅសម័យដើម គេតែងតាំងចាស់ទុំឲ្យណែនាំព្រះសហគមន៍នីមួយៗ ដើម្បីឲ្យព្រះសហគមន៍មានរបៀបរៀបរយ។ អ្នកណែនាំទាំងនោះពុំមែនជាបព្វជិត ដូចក្នុងព្រះសហគមន៍សព្វថ្ងៃទេ។ គេជឿថា មានព្រះគ្រីស្តតែមួយព្រះអង្គគត់ ជាមហាបូជាចារ្យ ហើយគ្រីស្តបរិស័ទទាំងអស់សុទ្ធតែជាបូជាចារ្យគឺគេយកការរស់នៅរបស់ខ្លួនថ្វាយទៅព្រះបិតា រួមនឹងសក្ការបូជារបស់ព្រះយេស៊ូ។ គួរឲ្យយើងនឹកថារបៀបចាត់ចែងការណែនាំព្រះសហគមន៍បានផ្លាស់ប្តូរជាច្រើនតាមកាលៈទេសៈ និងតាមសេចក្តីត្រូវការរបស់គ្រីស្តបរិស័ទ។

"គេរៀបរាប់អំពីកិច្ចការទាំងប៉ុន្មានដែលព្រះជាម្ចាស់បានធ្វើជាមួយលោក មិនមែនលោកនេះ ឬលោកនោះពូកែណែនាំឲ្យគេជឿ តែព្រះជាម្ចាស់វិញឯណោះទេដែលទាក់ទាញចិត្តគំនិតគេឲ្យផ្ញើជីវិតលើព្រះគ្រីស្ត។ យើងត្រូវតែអង្វរព្រះជាម្ចាស់ សូមព្រះអង្គបើកផ្លូវឲ្យប្រជាជនកម្ពុជាផ្ញើជីវិតលើព្រះគ្រីស្ត៕


## ដំណឹងជ្រើសរើសបុគ្គលិក

សាលា សន្តសាវីយេ ជាគម្រោងមួយរបស់អង្គការជេស្វីត សឺវវីស កម្ពុជា ដែលមានទីតាំងនៅក្នុងក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ត្រូវការជ្រើសរើស នាយក/នាយិកាសាលាបឋមសិក្សា និងមធ្យមសិក្សា ចំនួន១រូប។

លក្ខខណ្ឌជ្រើសរើស បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាគរុកោសល្យ(ផ្នែកបឋម) ឬសញ្ញាប័ត្របញ្ជាក់ថា ជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ហើយត្រូវមានបទពិសោធន៍បង្រៀនយ៉ាងតិច២ឆ្នាំឡើងទៅ។

ការជ្រើសរើសនេះនឹងចាប់ផ្តើមទទួលពាក្យចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦។ ប្រសិនបើបេក្ខជនមានចំណាប់អារម្មណ៍សូមទំនាក់ទំនង និងផ្ញើប្រវត្តិរូបសង្ខេប (CV) មកកាន់ការិយាល័យសាលា សន្តសាវីយេ ដោយផ្ទាល់ដែលមានអាស័យដ្ឋានស្ថិតនៅភូមិភ្នំបាក់ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។




ពត៌មានលំអិតសូមទំនាក់ទំនងមកកាន់ ប្រធានគម្រោងដោយផ្ទាល់តាមរយៈ

អ៊ីម៉ែល xjs.cambodia.manager@gmail.com និងលេខទូរស័ព្ទ 012 276 220 / 098 940 497 / 054 6333 588

# សូមគោរពជូនពរ

## លោកអភិបាលនៃព្រះសហគមន៍កាតូលិកទាំងបីភូមិភាគ
## ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ
## ឆ្នាំវក អដ្ឋស័ក ព.ស ២៥៦០



ដោយព្រះហឫទ័យ

ក្ដីប្រណីសន្ដោសដ៏លើសលប់របស់ព្រះជាម្ចាស់!

យើងខ្ញុំសូមទូលអង្វរព្រះជាម្ចាស់ជាព្រះបិតា ប្រោសប្រទានពរជ័យ ដល់លោកអភិបាលទាំងបី ឲ្យមានសុខភាពល្អ និងប្រាជ្ញាញាណភ្លឺថ្លា កម្លាំងកាយចិត្តមាំមួន និងបានពោរពេញដោយអំណរសប្បាយ ក្នុងបេសកកម្មប្រកាសដំណឹងល្អ និងណែនាំយើងខ្ញុំជាហ្វូងចៀមនៅប្រទេសកម្ពុជាឲ្យដើរត្រង់តាមមាគ៌ានៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ។

សូមគោរពជូនពរពី

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកកម្ពុជា





# រូបថតសកម្មភាពព្រះសហគមន៍កាតូលិក



